# សេចក្តីព្រាង

# គោលនយោបាយមេធាវីវ័យក្មេង




គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា

**ខែមិថុនា ឆ្នាំ២០២៤**

# មាតិកា


**បុព្វកថា** ........................................ ៤

**១- សេចក្តីផ្តើម** ........................................ ៦

១.១- សាវតា ........................................ ៦

១.២- ការរៀបចំគោលនយោបាយមេធាវីវ័យក្មេង ........................................ ៧

១.៣- ការរួមចំណែករបស់មេធាវីនៅក្នុងសង្គម ........................................ ១០

១.៤- ស្ថានភាពវិជ្ជាជីវៈមេធាវីបច្ចុប្បន្ន ........................................ ១១

១.៦- ជាតុផ្សំដើម្បីជោគជ័យជាមេធាវី ........................................ ១៣

១.៧- នរណាជាមេធាវីវ័យក្មេង ........................................ ១៤

១.៨- មូលហេតុនៃការចូលប្រកប ការរំពឹងទុក និងបញ្ហាប្រឈម ........................................ ១៤

១.៩- ដំណោះស្រាយលើបញ្ហាប្រឈម ........................................ ១៥

១.៧- លទ្ធផលនៃការសិក្សាតាមបណ្តាគណៈមេធាវីនៅបរទេស ........................................ ១៥

១.៨- លទ្ធផលនៃការស្ទង់មតិមេធាវីវ័យក្មេងនៅកម្ពុជា ........................................ ១៨

**២- ចក្ខុវិស័យ** ........................................ ២២

**៣- គោលបំណង** ........................................ ២២

**៤- ការវិភាគភាពខ្លាំង ភាពខ្សោយ កាលានុវត្តភាព និងការគំរាមកំហែង** ... ២៣

**៤- គោលដៅ** ........................................ ២៨

**៥- យុទ្ធសាស្ត្រ** ........................................ ២៩

**៦- ផែនការសកម្មភាព** ........................................ ៣០

៦.១- ការបង្កើតយន្តការ ........................................ ៣០

៦.២- ការបង្កើតក្របខណ្ឌគតិយុត្ត ........................................ ៣០

៦.៣- ការគាំទ្រហិរញ្ញវត្ថុ ........................................ ៣១

៦.៤- ការអភិវឌ្ឍធនធានមនុស្ស ........................................ ៣១


DRAFT

៦.៥- ដំណើរការអនុវត្ត ..... ៣១

**៧- ការតាមដានត្រួតពិនិត្យនិងការវាយតម្លៃ ..... ៣២**

**៨- សេចក្តីសន្និដ្ឋាន ..... ៣២**

**តារាងសកម្មភាពនៃក្របខ័ណ្ឌយុទ្ធសាស្ត្រ ..... ៣៤**

DRAFT

# បុព្វកថា

ក្នុងរយៈពេល ៣ ឆ្នាំចុងក្រោយនេះគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាសម្រេចបាននូវសមិទ្ធផលធំៗគួរជាទីមោទនៈ ដែលរួមចំណែកដល់ការពង្រីកនិងពង្រឹងការចូលរួមបម្រើវិស័យយុត្តិធម៌ និងការពង្រឹងនិងលើកកម្ពស់តម្លៃវិជ្ជាជីវៈ សមត្ថភាព ការលើកទឹកចិត្ត និងសុខុមាលភាពរបស់មេធាវី ដោយឈរលើស្មារតីនៃចក្ខុវិស័យ រួមគ្នាដើម្បីឧត្តមភាពនិងកិត្យានុភាពនៃវិជ្ជាជីវៈមេធាវី និងការអនុវត្តគោលនយោបាយ ៨ ចំណុច និងសកម្មភាពជាច្រើនទៀត។ តាមរយៈការអនុវត្តគោលនយោបាយ៨ចំណុចនេះ ការផ្តល់ជំនួយផ្នែកច្បាប់ជូនជនក្រីក្រ ស្ត្រី កុមារងាយរងគ្រោះ កម្មករនិងកម្មការិនី ត្រូវបានកើនឡើងគួរឱ្យកត់សម្គាល់តាមរយៈគោលនយោបាយមេធាវីស្ម័គ្រចិត្តរបស់គណៈមេធាវី កិច្ចសហប្រតិបត្តិការជាមួយក្រសួងយុត្តិធម៌ ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី និងដៃគូពាក់ព័ន្ធផ្សេងទៀត។ ការផ្សព្វផ្សាយច្បាប់ត្រូវបានធ្វើឡើងយ៉ាងទូលំទូលាយតាមរយៈសិក្ខាសាលា កម្មវិធីពាសំណួរ កម្មវិធីជជែកពីច្បាប់ កិច្ចពិភាក្សាតុមូល និងការបោះផ្សាយព្រឹត្តិបត្រមេធាវីជាដើម។ ចំណែកសមាជិកគណៈមេធាវីទទួលបានការទទួលស្គាល់នូវគុណបំណាច់ដែលមានចំពោះវិជ្ជាជីវៈមេធាវីនិងយុត្តិធម៌សង្គម តាមរយៈការផ្តល់គ្រឿងកិត្តិយសគណៈមេធាវី និងទទួលបានការលើកកម្ពស់សុខុមាលភាពតាមរយៈសេចក្តីសម្រេចផ្តល់តាវកាលិក ការសួរសុខទុក្ខនិងរំលែកទុក្ខជាដើម។ នៅក្នុងគណៈមេធាវី ប្រព័ន្ធរដ្ឋបាលត្រូវបានពង្រឹង ការផ្តល់សេវាដល់សមាជិកទាន់ពេលវេលា និងមានការបែងចែកការទទួលខុសត្រូវ និងរបៀបរបបការងារច្បាស់លាស់។ លើសពីនេះកិច្ចសហប្រតិបត្តិការទាំងក្នុងនិងក្រៅប្រទេសត្រូវបានពង្រឹងនិងពង្រីកតាមរយៈការចូលរួមសកម្មភាពគ្នាទៅវិញទៅមក និងចុះអនុស្សារណៈនៃការយោគយល់គ្នាជាដើម។ ខណៈសកម្មភាពនៅក្នុងសង្គមក៏មានសកម្មភាពយ៉ាងសកម្មតាមរយៈការចូលរួមបុណ្យជាតិ កម្មវិធីចង្ក្រានសប្បុរស និងបាយពេទ្យជាដើម។

បន្ទាប់ពីសម្រេចបានសមិទ្ធផលដ៏ត្រចះត្រចង់ខាងលើដល់សមាជិកគណៈមេធាវី គណៈមេធាវី វិជ្ជាជីវៈមេធាវី និងសង្គមជាតិ គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាបន្តបេសកកម្មរបស់ខ្លួនក្នុងការធានានិរន្តរភាពនូវ សមិទ្ធផលទាំងនោះ ព្រមទាំងកសាងគ្រឹះរឹងមាំ និងមានយុទ្ធសាស្ត្រច្បាស់លាស់ដើម្បីឆ្លើយតបទៅនឹងបរិវត្តកម្មសង្គម និងសេដ្ឋកិច្ច ព្រមទាំងបច្ចេកវិទ្យា កំណើននៃការប្រកួតប្រជែង និងការរំពឹងទុកពីសង្គមក៏ដូចជាកំណើននៃការប្រែប្រួល និងភាពស្មុគស្មាញនៃច្បាប់ និងពាណិជ្ជកម្មកម្រិតជាតិ និងសកលជាដើម។ អំឡុងពេលនៃការប្រែប្រួលនេះ តាមការស្រាវជ្រាវ មេធាវីវ័យក្មេងមានឧបសគ្គ និងការប្រឈមជាច្រើន ក្នុង

ការចាប់ផ្ដើមប្រកបវិជ្ជាជីវៈដំបូងរបស់ខ្លួនរួមមាន ឱកាសការងារ ឧបករណ៍សម្រាប់ប្រកបវិជ្ជាជីវៈនិងដំណើរការការិយាល័យមេធាវី ជំនាញក្នុងការរៀបចំផែនការហិរញ្ញវត្ថុ បញ្ហាសុខភាពផ្លូវចិត្ត ទំនាក់ទំនងក្នុងសង្គម រួមទាំងសមត្ថភាពក្នុងការប្រើប្រាស់បច្ចេកវិទ្យាថ្មីជាដើម។ ការណ៍នេះតម្រូវឱ្យគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាបន្តយកចិត្តទុកដាក់ខ្ពស់ចំពោះមេធាវីវ័យក្មេង ដែលជាទំពាំងស្នងឫស្សីសម្រាប់វិជ្ជាជីវៈមេធាវីនៅកម្ពុជានាពេលអនាគត។ ដើម្បីឆ្លើយតបទៅនឹងតម្រូវការនេះ ស្របតាមចក្ខុវិស័យរួមគ្នាដើម្បីឧត្តមភាពនិងកិត្យានុភាពនៃវិជ្ជាជីវៈមេធាវី និងការអនុវត្តគោលនយោបាយ ៨ ចំណុច ព្រមទាំងបទពិសោធន៍ និងនិន្នាការនៃការវិវឌ្ឍនៅក្នុងនិងក្រៅប្រទេស ដែលមានសមានគតិជាមួយនឹងស្ថានភាពកម្ពុជា គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាសម្រេចដាក់ចេញនូវគោលនយោបាយមេធាវីវ័យក្មេង ដែលមានចក្ខុវិស័យ **រួមគ្នាកសាងគ្រឹះនិងត្រួសត្រាយផ្លូវដល់មេធាវីវ័យក្មេងដើម្បីនិរន្តរភាពនៃឧត្តមភាពនិងកិត្យានុភាពនៃវិជ្ជាជីវៈមេធាវី** ក្នុងគោលបំណង **រួមចំណែកបម្រើសង្គមជាតិដោយផ្អែកលើច្បាប់និងវិធានវិជ្ជាជីវៈជាធរមាន តាមរយៈការកសាងប្រព័ន្ធអេកូឡូស៊ីដើម្បីគាំទ្រដល់ការប្រកបវិជ្ជាជីវៈ បង្កើនកាលានុវត្តភាពនិងឧត្តមភាពប្រកួតប្រជែងរបស់មេធាវីវ័យក្មេង។** ដើម្បីធានាបាននូវជោគជ័យនៃការអនុវត្តគោលនយោបាយនេះ អង្គភាពចំណុះគណៈមេធាវីទាំងអស់ ត្រូវចូលរួមឱ្យបានពេញលេញ សហការគ្នាជាធ្លុងមួយ ដោយមានការសម្របសម្រួលនិងពង្រឹងកិច្ចសហប្រតិបត្តិការប្រកបដោយស្មារតីបុរេសកម្ម អន្តរសកម្មបំផុត និងសហការទទួលខុសត្រូវខ្ពស់។

ក្នុងនាមគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ខ្ញុំសូមកោតសរសើរនិងវាយតម្លៃខ្ពស់ចំពោះក្រុមការងាររៀបចំគោលនយោបាយមេធាវីវ័យក្មេង ដែលបានចំណាយពេលសិក្សាស្រាវជ្រាវ ប្រជុំពិភាក្សាប្រមូលធាតុចូល និងតាក់តែងសេចក្ដីព្រាងគោលនយោបាយនេះរហូតក្លាយជារូបរាងឡើង។ ទន្ទឹមនេះ ខ្ញុំក៏សូមថ្លែងអំណរគុណចំពោះ សមាជិក-សមាជិកាគណៈមេធាវីទាំងអស់ដែលបានចូលរួមយ៉ាងសកម្មក្នុងការផ្ដល់ធាតុចូលតាមរយៈការស្ទង់មតិ និងការដាក់ពិគ្រោះយោបល់ ដែលរួមចំណែកធ្វើឱ្យគោលនយោបាយនេះឆ្លើយតបគ្រប់ជ្រុងជ្រោយនៃតម្រូវការរបស់មេធាវីវ័យក្មេង និងសង្គមជាតិ។

**ប្រធានគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា**

**ឯកឧត្តម លី ច័ន្ទតុលា**

DRAFT

# ១-    សេចក្តីផ្តើម

## ១.១- សាវតារ

នៅថ្ងៃទី១៥ ខែតុលា ឆ្នាំ២០២០ ឯកឧត្តម លី ច័ន្ទតុលា ត្រូវបានមហាសន្និបាតគណៈមេធាវី បោះឆ្នោតជាប្រធានគណៈមេធាវី។ ចក្ខុវិស័យរបស់ឯកឧត្តមក្នុងនាមជាប្រធានគណៈមេធាវីគឺ រួមគ្នាដើម្បីឧត្តមភាពនិងកិត្យានុភាពនៃវិជ្ជាជីវៈមេធាវី។ ដើម្បីសម្រេចបានចក្ខុវិស័យនេះ ឯកឧត្តមប្រធានបានដាក់ចេញនូវគោលនយោបាយដឹកនាំ៨ចំណុចៈ

១. រឹតបន្តឹងការសុំចូលប្រកបវិជ្ជាជីវៈមេធាវីតាមបទពិសោធន៍តាមមាត្រា៣២ នៃច្បាប់ស្តីពីលក្ខន្តិកៈមេធាវី និងការប្រឡងចូលរៀនវិជ្ជាជីវៈមេធាវីតាមមាត្រា៣១ នៃច្បាប់ស្តីពីលក្ខន្តិកៈមេធាវីដោយយកគុណភាព និងសមត្ថភាពជាគោល។

២. ពង្រឹងលើកកម្ពស់សមត្ថភាពមេធាវីតាមរយៈការបង្កើនវគ្គបណ្តុះបណ្តាល សិក្ខាសាលា ការដកស្រង់និងផ្លាស់ប្តូរបទពិសោធន៍ ទស្សនកិច្ចសិក្សា ទាំងក្នុងនិងក្រៅប្រទេស។

៣. ពង្រឹងកិច្ចសហការ ការផ្តល់តម្លៃនិងការយោគយល់គ្នាជាមួយស្ថាប័នជាតិ និងអន្តរជាតិ។

៤. បង្កើនការផ្សព្វផ្សាយឱ្យកាន់តែទូលំទូលាយអំពីតួនាទីមេធាវី និងកិច្ចការទាំងឡាយដែលអាចផ្តល់ឱ្យអតិថិជន។

៥. ពង្រីកទំហំការងារដែលមេធាវីអាចផ្តល់ឱ្យអតិថិជនឱ្យកាន់តែច្រើន និងប្រឆាំងនឹងការប្រកួតប្រជែងខុសច្បាប់ពីសំណាក់បុគ្គលដែលមិនមានសិទ្ធិជាមេធាវី។

៦. បង្កើតយន្តការផ្តល់តម្លៃនិងកិត្តិយសដល់មេធាវី ដែលមានស្នាដៃលេចធ្លោនៅក្នុងការជួយដល់គណៈមេធាវី វិជ្ជាជីវៈមេធាវី និងកិច្ចការយុត្តិធម៌សង្គម។

៧. បន្តអនុវត្តនិងពង្រីកយន្តការសុខុមាលភាពមេធាវីទាំងអស់ ជាពិសេសយន្តការទាក់ទងនឹងមូលនិធិសម្រាប់ជួយមេធាវីដែលមានវ័យចាស់និងមានជម្ងឺធ្ងន់ធ្ងរ។

៨. បង្កើនអន្តរកម្មរវាងគណៈមេធាវីនិងមេធាវី និងការផ្តល់សេវាឱ្យកាន់តែប្រសើរជូនមេធាវីទាំងអស់។

ការបង្កើតយន្តការជួយដល់មេធាវីវ័យក្មេងគឺដើម្បីឆ្លើយតបទៅនឹងបញ្ហាប្រឈមបច្ចុប្បន្ន និងកសាងមូលដ្ឋានគ្រឹះរឹងមាំប្រកបដោយនិរន្តរភាពសម្រាប់មេធាវីបន្តវេននៅពេលអនាគត ដែលជាអ្នកជានា ឧត្តម

DRAFT

ភាពនិងកិត្យានុភាពនៃវិជ្ជាជីវៈមេធាវី។ គណៈមេធាវីតែងតែយកចិត្តទុកដាក់ខ្ពស់លើមេធាវីវ័យក្មេង តាមរយៈយន្តការនានារួមមាន យន្តការគ្រូកម្មសិក្សា កិច្ចប្រជុំណែនាំដល់សហភាតាកំពុងធ្វើកម្មសិក្សា ពិធីសំណេះសំណាលនិងជជែកពិភាក្សាអំពីការប្រកបវិជ្ជាជីវៈមេធាវី កម្មវិធីបណ្តុះបណ្តាល និងកម្មវិធី សិក្ខាសាលាជាច្រើនដែលបង្កលក្ខណៈឱ្យមេធាវីវ័យក្មេងបានពង្រឹងចំណេះដឹង ទទួលបានបទពិសោធន៍ ល្អៗ និងមានឱកាសប្រាស្រ័យទាក់ទងជាមួយថ្នាក់ដឹកនាំគណៈមេធាវី និងមេធាវីដែលមានបទពិសោធន៍ ច្រើនឆ្នាំ។ ការបង្កើតយន្តការនេះជាការបន្ថែមទៅលើយន្តការដែលមានស្រាប់ ដើម្បីឆ្លើយតបទៅនឹង និន្នាការសង្គម សេដ្ឋកិច្ច និងសកលលោកដែលចាំបាច់តម្រូវឱ្យមានការសិក្សាស៊ីជម្រៅ និងកសាង យន្តការរឹងមាំសម្រាប់ជួយដល់មេធាវីបន្តវេន។

ការចាប់ផ្តើមសិក្សា និងកសាងយន្តការដើម្បីជួយមេធាវីវ័យក្មេងនេះគឺធ្វើឡើងបន្ទាប់ពីកិច្ចការនានាត្រូវបានសម្រេចដោយជោគជ័យសំដៅគាំទ្រដល់មេធាវីទាំងអស់ ព្រមទាំងវិជ្ជាជីវៈមេធាវីទាំងមូល រួមមានជាអាទិ៍ ការចេញសេចក្តីសម្រេចស្តីពីសុខុមាលភាពមេធាវី ការចុះសួរសុខទុក្ខមេធាវីដែលមានជម្ងឺ ជូនពរខួបកំណើតមេធាវី ជូនពរមេធាវីស្ត្រីដែលលំហែមាតុភាព ការចូលរួមរំលែកទុក្ខ ការរៀបចំកម្មវិធី កីឡា និងការបង្កើតគ្រឿងកិត្តិយសគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាជាដើម។ ហេតុនេះនៅឆ្នាំ ២០២៤នេះគឺជាពេលវេលាសមរម្យដែលឯកឧត្តមប្រធានកំណត់យកជាឆ្នាំដើម្បីកសាងគ្រឹះសម្រាប់មេធាវីបន្តវេន។

## ១.២- ការរៀបចំគោលនយោបាយមេធាវីវ័យក្មេង

នៅថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ២០២៤ តាមរយៈសេចក្តីសម្រេចលេខ ០៦៥/សសគម/២៤ **ឯកឧត្តម លី ច័ន្ទតុលា** ប្រធានគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា បានបង្កើតក្រុមការងាររៀបចំគោលនយោបាយមេធាវីវ័យក្មេង ដែលមានសមាភាពដូចខាងក្រោម៖

| | | | |
|---|---|---|---|
| ១. | **ឯកឧត្តម** | **លី ច័ន្ទតុលា** | **ប្រធាន** |
| ២. | លោកមេធាវី | សួង សុផល | អនុប្រធាន |
| ៣. | លោកមេធាវី | សួស សាមឿន | សមាជិក |
| ៤ | លោកស្រីមេធាវី | មុត ពិសិដ្ឋ | សមាជិកា |
| ៥. | លោកមេធាវី | គឹម វាសនា | សមាជិក |
| ៦. | លោកមេធាវី | កេង សុម៉ាឡា | សមាជិក |
| ៧. | លោកមេធាវី | លីម ស៊ីម | សមាជិក |

| | | | |
|---|---|---|---|
| ៨. | លោកមេធាវី | លី ទិត្យបូនាមី | សមាជិក |
| ១០. | លោកមេធាវី | យ៉ុន ប៊ុនណា | សមាជិក |
| ១១. | លោកមេធាវី | អ៊ឹង កិរិយា | សមាជិក |
| ១២. | លោកមេធាវី | ឃិច សមិទ្ធិ | សមាជិក |
| ១៣. | លោកស្រីមេធាវី | សេង រួចហ៊ុន | សមាជិកា |
| ១៤. | លោកមេធាវី | ធួន សុជា | សមាជិក |
| ១៥. | លោកស្រីមេធាវី | ជា សុកន្ធួន | សមាជិកា |
| ១៦. | លោកមេធាវី | កេត ច័ន្ទម៉ានីន | សមាជិក |
| ១៧. | លោកមេធាវី | លីវ សុវណ្ណា | សមាជិក |
| ១៨. | លោក | ឌិន ស៊ីដេន | សមាជិក |
| ១៩. | លោកជំទាវ | ឈីវ ភិរម្យ | សមាជិកា |
| ២០. | លោកមេធាវី | ប៉ា ងួនគា | សមាជិក |
| ២១. | លោកមេធាវី | វ៉ាន់ថាន់ ពៅដារ៉ា | សមាជិក |
| ២២. | លោកមេធាវី | គឹម រ័ត្នណារ៉ុង | សមាជិក |
| ២៣. | លោកមេធាវី | យូ លីមហួត | សមាជិក |
| ២៤. | លោកស្រីមេធាវី | ទេព បូផល | សមាជិកា |
| ២៥. | លោកស្រីមេធាវី | ម៉ី ឧសភា | សមាជិកា |
| ២៦. | លោកស្រីមេធាវី | សុខ វណ្ណសិកា | សមាជិកា |
| ២៧. | កញ្ញាមេធាវី | ដានី ច័ន្ទ្ររស្មីឈូករ័ត្ន | សមាជិកា |
| ២៨. | កញ្ញាមេធាវី | ឃឹម សុជាតា | សមាជិកា |
| ២៩. | កញ្ញាមេធាវី | បូរិន្ទ សុជាតា | សមាជិកា |
| ៣០. | លោកមេធាវី | វ៉ាំង ដួងជីវន្ត | សមាជិក |
| ៣១. | លោកមេធាវី | គីរី សេរីរដ្ឋ | សមាជិក |
| ៣២. | លោកមេធាវី | ហ៊ី សុខនី | សមាជិក |
| ៣៣. | លោកស្រីមេធាវី | សឿម សុរេន | សមាជិកា |
| ៣៤. | លោកមេធាវី | លឹម សំណាង[1] | សមាជិក |

[1] សេចក្តីសម្រេចស្តីពីការតែងតាំងសមាជិកក្រុមការងាររៀបចំគោលនយោបាយមេធាវីវ័យក្មេង លេខ១០៥/សសគម/២៤ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤

ក្រុមការងាររៀបចំគោលនយោបាយមេធាវីវ័យក្មេងមានតួនាទីនិងភារកិច្ចៈ

១. សិក្សាស្រាវជ្រាវពីតម្រូវការជាក់ស្តែងរបស់មេធាវីវ័យក្មេងដែលទើបចូលប្រកបវិជ្ជាជីវៈតិចជាងឬស្មើ៣ឆ្នាំ នៅព្រះរាជាណាចក្រកម្ពុជា
២. សិក្សាស្រាវជ្រាវនិងចងក្រងគោលការណ៍ គោលនយោបាយ ឬយន្តការនានា ដែលគណៈមេធាវីនៃបណ្តាប្រទេសផ្សេងបានរៀបចំដើម្បីជួយដល់មេធាវីវ័យក្មេង
៣. សិក្សាស្រាវជ្រាវនិងចងក្រងគោលការណ៍ គោលនយោបាយ ឬយន្តការនានា ដែលស្ថាប័នជាតិនិងអន្តរជាតិនានាបានរៀបចំដើម្បីជួយតម្រង់ទិសដល់យុវជន
៤. រៀបចំសេចក្តីព្រាងផែនទីបង្ហាញផ្លូវ គោលនយោបាយ និងផែនការសកម្មភាពសម្រាប់ជួយដល់មេធាវីវ័យក្មេងដែលទើបចូលប្រកបវិជ្ជាជីវៈតិចជាងឬស្មើ៣ឆ្នាំ នៅព្រះរាជាណាចក្រកម្ពុជា ដើម្បីដាក់ជូនប្រធានពិនិត្យនិងសម្រេច
៥. បំពេញភារកិច្ចផ្សេងៗទៀត តាមការកំណត់របស់ប្រធានគណៈមេធាវី។

បន្ទាប់ពីក្រុមការងាររៀបចំគោលនយោបាយមេធាវីវ័យក្មេងត្រូវបានបង្កើតឡើង ឯកឧត្តមប្រធានបានដឹកនាំកិច្ចប្រជុំរបស់ក្រុមការងារជារៀងរាល់សប្តាហ៍ដើម្បីប្រមូលធាតុចូល បែងចែកតួនាទីភារកិច្ចក្នុងការតាក់តែង សិក្សាស្រាវជ្រាវ និងស្ទង់មតិ។ ជាលទ្ធផល ក្រុមការងារបានសិក្សាស្រាវជ្រាវអំពី ក្របខ័ណ្ឌគតិយុត្ត គោលនយោបាយ រួមទាំងតថភាពជាក់ស្តែងនៅកម្ពុជា គណៈមេធាវីកម្ពុជា និងវិជ្ជាជីវៈមេធាវីនៅកម្ពុជាទាំងមូល។ ក្រុមការងារក៏បានសិក្សាស្រាវជ្រាវនិងចងក្រងយន្តការនៅតាមបណ្តាស្ថាប័នគណៈមេធាវីនៅបរទេស និងស្ថាប័នអន្តរជាតិនានារួមមានពីប្រទេសអង់គ្លេស សហរដ្ឋអាមេរិក ម៉ាឡេស៊ី សិង្ហបុរី កូរ៉េខាងត្បូង ជប៉ុន ថៃ និងសមាគមច្បាប់អាស៊ីនិងប៉ាស៊ីហ្វិក (The Law Association for Asia and the Pacific – LAWASIA) និងគណៈមេធាវីអន្តរជាតិ (International Bar Assocation – IBA)។ លើសពីនេះការស្ទង់មតិលម្អិតអំពីបញ្ហាប្រឈមនិងសំណូមពរពីសមាជិកមេធាវីវ័យក្មេងនៅកម្ពុជាទាំងអស់ រួមទាំងការសិក្សាលម្អិតអំពីអត្ថបទស្រាវជ្រាវនានាត្រូវបានធ្វើឡើងផងដែរ។ លទ្ធផលនៃការស្រាវជ្រាវ និងធាតុចូលពីសំណាក់ក្រុមការងារគឺជាមូលដ្ឋានដ៏សំខាន់ក្នុងការតាក់តែង សេចក្តីព្រាងគោលនយោបាយដែលឆ្លើយតបទៅនឹងតម្រូវការរបស់មេធាវីវ័យក្មេង តថភាពសង្គមជាក់ស្តែង និងស្របទៅនឹងការវិវត្តន៍ជាលក្ខណៈអន្តរជាតិ។ សេចក្តីព្រាងគោលនយោបាយនេះក៏ត្រូវបានដាក់ពិគ្រោះយោបល់ជាមួយសមាជិក

DRAFT

មេធាវីនៃគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាទាំងអស់ ដើម្បីធានានូវភាពពេញលេញគ្រប់ជ្រុងជ្រោយ មុនដាក់ជូនក្រុមប្រឹក្សាគណៈមេធាវីពិនិត្យនិងសម្រេចដាក់ឱ្យអនុវត្ត។

## ១.៣- ការរួមចំណែករបស់មេធាវីនៅក្នុងសង្គម

មេធាវីជាតួអង្គដ៏សំខាន់នៅក្នុងសង្គម ដែលសារៈសំខាន់និងការរួមចំណែករបស់មេធាវីភាគច្រើនមិនបានផ្សព្វផ្សាយ និងស្វែងយល់ឱ្យបានទូលំទូលាយ។ ទាំងនេះដោយហេតុថាមានកង្វះខាតក្នុងការកត់សម្គាល់ ហើយសារៈសំខាន់មួយចំនួនពុំអាចមើលឃើញដោយភ្នែកទទេបាន។ មេធាវីបានចូលរួមចំណែកក្នុងសង្គមរួមមាន ការចូលរួមផ្នែកសេដ្ឋកិច្ច ការចូលរួមក្នុងដំណើរការស្វែងរកយុត្តិធម៌ ការចូលរួមក្នុងគ្រាមានអាសន្ន ការចូលរួមក្នុងគោលនយោបាយសាធារណៈ ការចូលរួមក្នុងសង្គមនិងសហគមន៍។ ចំពោះការចូលរួមផ្នែកសេដ្ឋកិច្ច វិស័យច្បាប់មិនត្រឹមតែបង្កើតការងារផ្ទាល់ដល់មេធាវីនោះទេ ប៉ុន្តែរួមទាំងបុគ្គលិកដែលបម្រើការនៅការិយាល័យមេធាវី និងអ្នកផ្គត់ផ្គង់សេវានិងទំនិញដល់ការិយាល័យនោះ ហើយសេវាផ្នែកច្បាប់ជាផ្នែកមួយដែលរួមចំណែកបង្កើនកំណើនសេដ្ឋកិច្ចក្នុងចំណោមវិស័យផ្សេងៗផងដែរ។ ក្នុងនោះ ប្រព័ន្ធច្បាប់ដែលមានប្រសិទ្ធភាពនឹងនាំឱ្យមានកំណើនសេដ្ឋកិច្ចខ្ពស់ ជាក់ស្តែងអនុលោមភាពច្បាប់ និងអាជីវកម្មដែលត្រូវបានរៀបចំឡើង និងមានរចនាសម្ព័ន្ធគ្រប់គ្រងត្រឹមត្រូវនឹងផ្តល់អត្ថប្រយោជន៍ដល់សេដ្ឋកិច្ចប្រទេសជាតិ ព្រមទាំងភាគីពាក់ព័ន្ធរបស់ក្រុមហ៊ុនរួមមាន ម្ចាស់បំណុល ម្ចាស់ភាគហ៊ុន បុគ្គលិក និងអ្នកប្រើប្រាស់។ រីឯការចូលរួមក្នុងដំណើរការស្វែងរកយុត្តិធម៌ មេធាវីបានផ្តល់ជំនួយផ្នែកច្បាប់ដល់ជនក្រីក្រ អនីតិជន ស្ត្រីងាយរងគ្រោះ ព្រមទាំងក្រុមគ្រួសារ តាមរយៈការតំណាង ការជួយការពារ និងប្រឹក្សាយោបល់រឿងក្តី ទាំងរឿងព្រហ្មទណ្ឌ និងរដ្ឋប្បវេណី ដោយឥតយកកម្រៃ។ កិច្ចការរបស់មេធាវីស្ម័គ្រចិត្តទាំងអស់នេះគឺមានសារៈសំខាន់ដើម្បីធានាសុខភាព ភាពសុខដុមរមនា និងសន្តិភាពនៅក្នុងសង្គម។ ចំពោះការចូលរួមក្នុងគ្រាមានអាសន្ន មេធាវីក៏ដើរតួសំខាន់ក្នុងការជួយសង្គមក្នុងគ្រាមានអាសន្ន ឬ គ្រោះធម្មជាតិដូចជាវិបត្តិនៃការរីករាលដាលជម្ងឺកូវីដ១៩ គ្រោះទឹកជំនន់ជាដើម ដែលមេធាវីនាំគ្នាជួយតាមរយៈការបរិច្ចាគទ្រព្យសម្បត្តិ សម្ភារ និងពេលវេលាក្នុងការចូលរួមជាមួយអាជ្ញាធរមានសមត្ថកិច្ចដើម្បីឆ្លើយតបទៅនឹងវិបត្តិ ក៏ដូចជាគ្រោះធម្មជាតិនេះទាំងអស់គ្នា។ រីឯការចូលរួមក្នុងគោលនយោបាយសាធារណៈ មេធាវីមិនត្រឹមតែធ្វើការនៅក្នុងសវនាការតុលាការនោះទេ តែក៏ចូលរួមក្នុងការអភិវឌ្ឍច្បាប់ បទប្បញ្ញត្តិ ដែលប៉ះពាល់ដល់អាជីវកម្ម បុគ្គល សហគមន៍ និងបរិស្ថានផងដែរ។ ចំពោះការចូលរួមក្នុងសង្គមនិងសហគមន៍ មេធាវីមានសារៈសំខាន់សម្រាប់មូលធនសង្គមនៅក្នុង

សហគមន៍តាមរយៈការជួយបុគ្គល និងស្ថាប័នក្នុងការដំណើរការក្នុងប្រព័ន្ធច្បាប់ស្មុគស្មាញ ហើយពេលខ្លះក្នុងពេលដែលមានបញ្ហាផ្លូវចិត្ត និងហិរញ្ញវត្ថុ ហើយមេធាវីក៏ជួយដល់បុគ្គលដែលមានបញ្ហាផ្លូវចិត្តខ្ពស់ដែលឆ្លងកាត់វិវាទដែលប៉ះពាល់ផ្លូវចិត្តខ្លាំង ហើយតម្រូវឱ្យមានការស្វែងយល់និងយកចិត្តទុកដាក់ខ្ពស់ដល់ជនរងគ្រោះ ឬកូនក្តី ដែលក្នុងន័យនេះមេធាវីនឹងរួមចំណែកដ៏សំខាន់លើកត្តាដែលនឹងផ្លាស់ប្តូរជីវិតរបស់បុគ្គលទាំងនោះ។

## ១.៤- ស្ថានភាពវិជ្ជាជីវៈមេធាវីបច្ចុប្បន្ន

### ១.៤.១- កម្រិតសកល

នៅឆ្នាំ២០២៤នេះ ទីផ្សារសម្រាប់សេវាកម្មផ្នែកច្បាប់សកលត្រូវបានព្យាករមានទំហំប្រមាណ ៩៣៦ ពាន់លានដុល្លារអាមេរិក។ [2] ប្រទេសអភិវឌ្ឍន៍នាំមុខគេបង្អស់ក្នុងការផ្តល់សេវាកម្មផ្នែកច្បាប់ ជាក់ស្តែងនៅឆ្នាំ២០១៧ សហរដ្ឋអាមេរិកគ្របដណ្តប់ស្មើរតែពាក់កណ្តាលនៃទំហំទីផ្សារសរុប និងបន្តដោយតំបន់អឺរ៉ុប។ សម្រាប់ទីផ្សារអាស៊ីរំពឹងថានឹងមានកំណើននាំមុខវិញនៅឆ្នាំខាងមុខ។

ទីផ្សារផ្នែកច្បាប់ត្រូវបានព្យាករថា[3] នឹងមាន ១) កំណើនខ្ពស់លើវិស័យធំៗរួមមាន អនុលោមភាពច្បាប់ ការរួមបញ្ចូលនិងទិញក្រុមហ៊ុន និងការដោះស្រាយវិវាទ ២) កំណើននៃការប្រើប្រាស់សេវាផ្សេងជំនួសលើសេវាច្បាប់ ៣) ការស្វែងយល់អំពីទិន្នន័យនឹងមានសារៈសំខាន់ដូចយល់អំពីច្បាប់ ៤) កំណើននៃការប្រើប្រាស់បច្ចេកវិទ្យាថ្មីៗនៅក្នុងដំណើរការប្រចាំថ្ងៃ ៥) ផលិតភាពការងារនឹងមានការវាយតម្លៃតឹងរ៉ឹងដោយផ្អែកលើ KPI ។

### ១.៤.២- កម្រិតជាតិ

នៅកម្ពុជា គិតត្រឹមខែធ្នូ ឆ្នាំ២០២៣ សមាជិកគណៈមេធាវី និងមេធាវីកម្មសិក្សាមានចំនួនសរុប ៣ ០០៣នាក់[4] ដែលក្នុងចំនួននេះ មេធាវីពេញសិទ្ធិកំពុងប្រកបវិជ្ជាជីវៈមេធាវីមានចំនួនតែ ២ ៤៧៨នាក់

---

[2] https://www.statista.com/statistics/605125/size-of-the-global-legal-services-market/

[3] https://www2.deloitte.com/content/dam/Deloitte/ro/Documents/about-deloitte/Legal_future_trends_for_legal_services.pdf , https://kpmg.com/xx/en/home/insights/2020/12/future-of-legal-article-series.html

[4] មេធាវីពេញសិទ្ធិកំពុងប្រកបវិជ្ជាជីវៈ មានចំនួន ២ ៤៧៨ នាក់ មេធាវីកំពុងកម្មសិក្សាមានចំនួន ២៨៩ នាក់ មេធាវីសុំមិនប្រកបមានចំនួន ១៩១ នាក់ មេធាវីសុំនៅក្រៅបញ្ជីមានចំនួន ២០ នាក់។

ប៉ុណ្ណោះ(ប្រុស ១ ៨៤៩នាក់ និងស្ត្រី ៦២៩នាក់) គឺស្មើនឹងជាង៨០%នៃចំនួនមេធាវីសរុប ដែលក្នុងនោះ មេធាវីកំពុងប្រកបវិជ្ជាជីវៈមានអាយុច្រើនជាង៦៥ឆ្នាំ មានចំនួន ៧២នាក់ (ប្រុស ៦៣នាក់ និងស្រី ៩នាក់)។ ក្នុងនោះមេធាវីដែលមានអាយុក្រោម៣៥ឆ្នាំ មានចំនួន ៨៤១ នាក់ (ប្រុស ៥៤១នាក់ និងស្រី៣០០នាក់)។

*តារាងបែងចែកអាយុរបស់មេធាវីពេញសិទ្ធិកំពុងប្រកវិជ្ជាជីវៈមេធាវី*

| **មេធាវីសរុប** | **អាយុក្រោម៣៥ឆ្នាំ** | | **អាយុ៣៥ ដល់ ៦៥ ឆ្នាំ** | | **អាយុពី៦៥ឆ្នាំឡើង** | |
|---|---|---|---|---|---|---|
| | ស្រី | ប្រុស | ស្រី | ប្រុស | ស្រី | ប្រុស |
| ២ ៤៧៨ នាក់ | ៣០០ | ៥៤១ | ៣២០ | ១ ២៤៥ | ៩ | ៦៣ |
| | ៨៤១ នាក់ | | ១ ៥៦៥ នាក់ | | ៧២ នាក់ | |

## ១.៥- ក្របខ័ណ្ឌគោលនយោបាយនិងបរិបទកម្ពុជាបច្ចុប្បន្ន

យោងតាមកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា សម្រាប់ការកសាង និងការការពារមាតុភូមិឆ្នាំ២០២៣-២០២៨ រួមមានគោលដៅយុទ្ធសាស្ត្រពាក់ព័ន្ធនឹងការកសាងសង្គមដោយផ្អែកលើច្បាប់ សេដ្ឋកិច្ចរីកចម្រើន សុខដុមរមនា និងគោរពសិទ្ធិមនុស្ស។ រីឯគោលនយោបាយធំៗជាអាទិភាពដែលពាក់ព័ន្ធរួមមានការលើកកម្ពស់ជីវភាពប្រជាជនគ្រប់រូបទាំងខាងសម្ភារនិងស្មារតី ឱ្យបានសមរម្យប្រកបដោយភាពថ្លៃថ្នូរ និងការលើកស្ទួយលទ្ធិប្រជាធិបតេយ្យ សិទ្ធិសេរីភាពប្រជាជន និងពង្រឹងនីតិរដ្ឋ ក៏ត្រូវការមេធាវីឱ្យចូលរួមដើម្បីសម្រេចបាននូវគោលដៅនោះដែរ។ ចំពោះគោលនយោបាយអភិវឌ្ឍតាមវិស័យរួមមានការធ្វើពិពិធកម្មសេដ្ឋកិច្ច ការជំរុញការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធឌីជីថល ការជំរុញឌីជីថលូបនីយកម្មសេដ្ឋកិច្ចនិងសង្គម ការជំរុញពាណិជ្ជកម្មអន្តរជាតិ និងការអភិវឌ្ឍវិស័យឯកជន ក៏តម្រូវឱ្យមានការចូលរួមខ្ពស់ពីមេធាវីផងដែរ។

កម្ពុជាបានបំពេញគ្រប់លក្ខខណ្ឌជាលើកដំបូងនៅឆ្នាំ២០២១ ដែលអាចចាកចេញពីប្រទេសអភិវឌ្ឍន៍តិចតួចនៅឆ្នាំ២០២៧ ឬឆ្នាំ២០២៨ ដោយយោងទៅលើការវាយតម្លៃរបស់គណៈកម្មាធិការគោលនយោបាយអភិវឌ្ឍន៍។ ការចាកចេញនេះនឹងនាំមកនូវទាំងឱកាស និងបញ្ហាប្រឈមចំពោះកម្ពុជាជាប្រាកដ ដែល

DRAFT

តម្រូវឱ្យមានមេធាវីវ័យក្មេងបន្តវេនដើម្បីចូលរួមចាប់យកឱកាស ក៏ដូចជាដោះស្រាយបញ្ហាប្រឈមឱ្យស្រប តាមសភាពការណ៍ជាក់ស្តែងនាឱកាសនោះ។

ប្រទេសកម្ពុជាបានក្លាយជាសមាជិកប្រទេសសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ ហៅកាត់ថា "**អាស៊ាន**" នៅឆ្នាំ១៩៩៩ និងបានក្លាយជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោកនៅឆ្នាំ២០០៤។ ក្នុងបរិបទអាស៊ាន ប្រទេសកម្ពុជាបានយល់ព្រមចុះកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន(AFTA) និងជាពិសេសគឺកិច្ចព្រមព្រៀងស្តីពីពាណិជ្ជកម្មលើសេវាកម្មអាស៊ាន (ASEAN Trade in Services Agreement-ATISA)។ រីឯក្នុងបរិបទនៃពាណិជ្ជកម្មអន្តរជាតិ រួមមានកិច្ចព្រមព្រៀងដៃគូសេដ្ឋកិច្ចទូលំទូលាយ(Regional Comprehensive Economic Partnership-RCEP) រវាងប្រទេសអាស៊ានទាំង១០ និងប្រទេសជាដៃគូទាំង៥។ បន្ថែមពីនេះ ប្រទេសកម្ពុជាក៏បានចុះកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីជាមួយបណ្តាប្រទេសជាដៃគូមួយចំនួនផងដែរ ដែលតាមរយៈនេះអាចបង្កើនទំនាក់ទំនងវិនិយោគ និងពាណិជ្ជកម្មរវាងបណ្តាប្រទេសជាភាគីនៃកិច្ចព្រមព្រៀងទាំងនេះ។ ការផ្តល់សេវាកម្មប្រឹក្សាច្បាប់សម្រាប់ធុរកិច្ចជនបរទេស ក៏ត្រូវបានចែង និងកំណត់នៅក្នុងកិច្ចព្រមព្រៀងទាំងនោះ ដែលជាការបើកទីផ្សារការងាររបស់មេធាវីកម្ពុជា។ ក្នុងន័យនេះ កាលានុវត្តភាពនឹងកើនឡើង ចំណែកកំណើននៃការប្រកួតប្រជែងនឹងកើនឡើងកាន់តែខ្ពស់ផងដែរ ដែលតម្រូវឱ្យមេធាវីវ័យក្មេងរបស់យើងបច្ចុប្បន្ន បង្កើនឧត្តមភាពប្រកួតប្រជែងរបស់ខ្លួនដើម្បីចាប់ទាញយកកាលានុវត្តភាពពីការវិវត្តន៍ទាំងនោះ ជាជាងក្លាយជាជនរងគ្រោះ។

## ១.៦- ជាតុផ្សំដើម្បីជោគជ័យជាមេធាវី

បេសកកម្មរបស់មេធាវីចម្បងគឺចូលរួមបម្រើវិស័យយុត្តិធម៌ ពោលគឺដើម្បីប្រយោជន៍សាធារណៈ។ អត្ថបទជាច្រើនផ្តោតភាពជោគជ័យរបស់មេធាវីលើចំណេះដឹង និងជំនាញក្នុងការប្រកបវិជ្ជាជីវៈ ខណៈពេលដែលមានអត្ថបទស្រាវជ្រាវជាច្រើនរកឃើញអំពីបញ្ហាផ្លូវចិត្ត និងផាសុខភាពរបស់មេធាវីក្នុងការប្រកបវិជ្ជាជីវៈ ហើយមានអត្ថបទជាច្រើនទៀតផ្តល់គន្លឹះក្នុងការបើកដំណើរការការិយាល័យមេធាវី និងធ្វើការក្នុងការិយាល័យមេធាវីជាដើម។ ហេតុនេះពុំមានការឯកភាពជាសកលអំពីជាតុផ្សំដើម្បីភាពជោគជ័យរបស់មេធាវីនោះទេ ដោយនិយមន័យនិងជាតុផ្សំនៃភាពជោគជ័យនេះ គឺអាស្រ័យទៅតាមការយល់ឃើញរបស់ស្ថាប័នផ្សេងៗគ្នា។ ក្នុងបរិបទនៃការរៀបចំគោលនយោបាយនេះ ដោយពិចារណាទៅលើបេសកកម្មចម្បងនិងអត្ថបទលើផ្នែកផ្សេងៗ ផ្នែកសំខាន់ៗសម្រាប់ជោគជ័យជាមេធាវីរួមមាន ការប្រកបវិជ្ជាជីវៈ

មេធាវី គុណភាពជីវិត ការបើកដំណើរការការិយាល័យមេធាវី(ជម្រើស) និងការចូលរួមបម្រើសង្គមដើម្បីផលប្រយោជន៍សាធារណៈ។

## ១.៧- នរណាជាមេធាវីវ័យក្មេង

មេធាវីវ័យក្មេងសំដៅលើមេធាវីដែលស្ថិតនៅក្នុងចន្លោះអាយុមួយ និងមេធាវីថ្មីដែលទើបបានចូលប្រកបវិជ្ជាជីវៈក្នុងចន្លោះរយៈពេលមួយ ដែលត្រូវបានចាត់ទុកថាជាវ័យក្មេងក្នុងក្របខ័ណ្ឌវិជ្ជាជីវៈ។ ចន្លោះអាយុ និងចន្លោះរយៈពេលទើបចូលប្រកប ពុំទាន់ត្រូវបានកំណត់ឱ្យមានលក្ខណៈរួមជាសកលនោះទេ ពោលគឺមានការកំណត់ផ្សេងៗគ្នាតាមបណ្ដាស្ថាប័នផ្សេងៗគ្នា។ គណៈមេធាវីអន្តរជាតិបានកំណត់មេធាវីដែលមានអាយុ ៣៥ឆ្នាំ ឬក្រោមនេះគឺជាមេធាវីវ័យក្មេង ចំណែកគណៈមេធាវីអាហ្វ្រិកខាងត្បូងកំណត់យកអាយុ ៣៥ឆ្នាំ ឬក្រោមនេះ ប៉ុន្តែទើបចូលប្រកបវិជ្ជាជីវៈបានតិចជាង ៥ឆ្នាំ។ ចំណែកនៅអូស្ត្រាលីកំណត់យកអាយុ ៣៥ឆ្នាំ ឬក្រោមនេះ។ ចំពោះសហរដ្ឋអាមេរិកកំណត់យកអាយុក្រោម ៣៦ឆ្នាំ ឬមេធាវីដែលបានទទួលការអនុញ្ញាតឱ្យប្រកបវិជ្ជាជីវៈតិចជាង ៥ឆ្នាំ។ ផ្អែកតាមទិន្នន័យនេះ យើងកំណត់និយមន័យមេធាវីវ័យក្មេងបានថាជាមេធាវីដែលមានអាយុ ៣៥ឆ្នាំ ឬក្រោមនេះ ឬមេធាវីដែលទើបទទួលបានការអនុញ្ញាតឱ្យប្រកបវិជ្ជាជីវៈតិចជាង ៥ឆ្នាំ។

ក្នុងក្របខ័ណ្ឌគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា មេធាវីវ័យក្មេងសំដៅលើមេធាវីដែលបានចូលប្រកបក្រោមរយៈពេល ៣ឆ្នាំ គិតចាប់ពីថ្ងៃអនុញ្ញាតឱ្យធ្វើកម្មសិក្សា ឬសេចក្ដីសម្រេចឱ្យរួចពីកម្មសិក្សា។ ការកំណត់បែបនេះដោយហេតុ ថានៅកម្ពុជាយើងមានប្រព័ន្ធកម្មសិក្សា។ ហេតុនេះគោលនយោបាយនឹងកំណត់សកម្មភាពដែលត្រូវធ្វើភ្លាមៗ ដើម្បីជួយមេធាវីវ័យក្មេងនៅពេលចាប់ផ្ដើមធ្វើកម្មសិក្សាភ្លាម។

## ១.៨- មូលហេតុនៃការចូលប្រកប ការរំពឹងទុក និងបញ្ហាប្រឈម

យោងតាមការស្រាវជ្រាវរបស់គណៈមេធាវីអន្តរជាតិ ភាគច្រើននៃមេធាវីគឺចូលប្រកបវិជ្ជាជីវៈមេធាវីភ្លាមៗបន្ទាប់ពីបញ្ចប់ការសិក្សា ហើយភាគតិចចូលប្រកបចន្លោះពី ២ឆ្នាំ ទៅ៤ឆ្នាំ បន្ទាប់ពីបញ្ចប់ការសិក្សា។ កត្តាដែលជំរុញឱ្យចូលក្នុងវិជ្ជាជីវៈមេធាវីរួមមាន កត្តាចំណាប់ចំណូលចិត្តផ្ទាល់ខ្លួន កត្តាបទពិសោធន៍ការងារ កត្តាឱកាសក្នុងការទទួលបានប្រាក់បៀវត្សច្រើន កត្តាបំណងចង់ធ្វើការនៅក្នុងសាលសវនាការ និងស្ថិរភាពការងារ កត្តាការរំពឹងទុកពីគ្រួសារ មិត្តភក្តិ និងក្រុមការងារ និងកត្តាបទពិសោធន៍ពីសាលា។

ចំពោះការរំពឹងទុកវិញ កត្តាដែលទាក់ទាញមេធាវីវ័យក្មេងទៅធ្វើការរួមមាន ប្រាក់បៀវត្ស កន្លែងធ្វើការដែលលើកកម្ពស់តុល្យភាពការងារនិងជីវិតប្រកបដោយផាសុខភាព ភាពសម្បូរបែបនៃការងារ ឱកាសក្នុងការធ្វើដំណើរនិងធ្វើការនៅក្រៅប្រទេស បែបបទការងារមានភាពបត់បែន ទីតាំងនៃកន្លែងធ្វើការ អត្រារក្សាបុគ្គលិកខ្ពស់ ការគាំទ្រក្នុងការអភិវឌ្ឍវិជ្ជាជីវៈឬអាជីពជាប្រចាំ។

ចំណែកបញ្ហាប្រឈមវិញនោះគឺ កង្វះការអភិវឌ្ឍ/ការបណ្តុះបណ្តាលវិជ្ជាជីវៈ វប្បធម៌នៅកន្លែងធ្វើការមានកម្រិតទាប កត្តាប្រាក់បៀវត្ស កង្វះឱកាសអភិវឌ្ឍអាជីព កត្តាបន្ទុកការងារ/ខ្វះតុល្យភាពជីវិត បំណងធ្វើការនៅក្រៅប្រទេស ចំណង់ចំណូលចិត្តក្នុងការប្តូរទៅវិជ្ជាជីវៈច្បាប់ផ្សេងទៀត ផលប៉ះពាល់លើសុខភាពផ្លូវចិត្ត/ផាសុខភាព។ លើសពីនេះបញ្ហាប្រឈមផ្សេងទៀតរួមមាន ផែនការហិរញ្ញវត្ថុ ការទំនាក់ទំនងជំនាញសម្ភាសន៍ កង្វះការបណ្តុះបណ្តាលក្នុងការដំណើរការអាជីវកម្ម ដំណើរការការិយាល័យមេធាវីឬប្រកបវិជ្ជាជីវៈច្បាប់ ជាដើម។

## ១.៩- ដំណោះស្រាយលើបញ្ហាប្រឈម

ដំណោះស្រាយដើម្បីឆ្លើយតបទៅបញ្ហាប្រឈមខាងលើ គណៈមេធាវីត្រូវបានរំពឹងថា ផ្តល់សេវាលក្ខណៈបុគ្គលដល់សមាជិកមេធាវី បង្កើតធនធានដែលងាយរក ឱកាសបង្កើតទំនាក់ទំនងលក្ខណៈក្រៅផ្លូវការ ឱកាសទំនាក់ទំនងជាមួយមេធាវីដែលមានបទពិសោធន៍ ការប្រឹក្សាយោបល់លើអាជីព ព្រមទាំងធានាស្តង់ដារគុណភាពបច្ចេកទេសក្នុងការប្រកបវិជ្ជាជីវៈរបស់មេធាវីផងដែរ។ លើសពីនេះចំណុចផ្សេងទៀតរួមមាន សារៈសំខាន់នៃប្រាក់បៀវត្ស តុល្យភាពជីវិតនិងការងារនិងផាសុខភាពផ្លូវចិត្ត ការអភិវឌ្ឍអាជីពនិងបច្ចេកវិទ្យា វប្បធម៌កន្លែងការងារ ការទំនាក់ទំនងនិងវាយតម្លៃ ដាក់ចេញនិងពិនិត្យឡើងវិញលើគោលនយោបាយ គំនិតផ្តួចផ្តើម និងការបណ្តុះបណ្តាល។

## ១.១០- លទ្ធផលនៃការសិក្សាតាមបណ្តាគណៈមេធាវីនៅបរទេស

ព័ត៌មានខាងក្រោមជាសង្ខេបអំពីយន្តការនានាដើម្បីជួយមេធាវីវ័យក្មេងនៅតាមបណ្តាគណៈមេធាវីបរទេស។ រចនាសម្ព័ន្ធគណៈមេធាវីនៅតាមប្រទេសនីមួយៗមានលក្ខណៈខុសៗគ្នា រួមទាំងព័ត៌មានដែលមានជាសាធារណៈផងដែរ។ ហេតុនេះព័ត៌មានខាងក្រោមប្រើប្រាស់ដើម្បីជាសញ្ញាណតែប៉ុណ្ណោះ ពុំមានគោលបំណងប្រើប្រាស់ជាឯកសារយោងនោះទេ។

| | |
|---|---|
| អង់គ្លេស | - នាយកដ្ឋានមេធាវីវ័យក្មេង<br>- កម្មវិធីមានគ្រូដឹកនាំ និងណែនាំ<br>- ការអភិវឌ្ឍវិជ្ជាជីវៈបន្ត<br>- ភាពចម្រុះ និងបរិយាបន្ន<br>- ធនធាន និងសហគមន៍អនឡាញ<br>- - ឱកាសការងារស្ម័គ្រចិត្តក្នុងវិស័យច្បាប់ |
| សហរដ្ឋអាមេរិក | - គណៈកម្មាធិការមេធាវីវ័យក្មេង<br>- ផ្តល់ជំនួយលើការស្វែងរកឱកាសការងារនិងទីផ្សារ<br>- ផ្តល់ជំនួយលើការរៀបចំ ពង្រឹងជំនាញ និងការគ្រប់គ្រងលើការប្រកបវិជ្ជាជីវៈមេធាវី<br>- ផ្តល់ជំនួយលើធនធានចំណេះដឹងនិងឯកសារ<br>- រៀបចំការផ្តល់ពានរង្វាន់ផ្សេងៗដល់មេធាវីវ័យក្មេង |
| ថៃ | - គណៈកម្មាធិការមេធាវីវ័យក្មេង<br>- ការប្រកួតប្រជែងផ្នែកស្រាវជ្រាវ និងសរសេរអត្ថបទ<br>- កម្មវិធីបង្កើនទំនាក់ទំនងរវាងមេធាវី<br>- មូលនិធិជំនួយផ្នែកច្បាប់ |
| LAWASIA | - ពុំមានយន្តការជាក់លាក់ដើម្បីជួយដល់មេធាវីវ័យក្មេង |
| ម៉ាឡេស៊ី | - គណៈកម្មាធិការជាតិមេធាវីវ័យក្មេង<br>- រៀបចំសកម្មភាពដើម្បីលើកកម្ពស់ចំណងមិត្តភាព និងសាមគ្គីភាពរវាងមេធាវីវ័យក្មេងទូទាំងប្រទេស<br>- រៀបចំសិក្ខាសាលា និងវគ្គបណ្តុះបណ្តាលដែលអភិវឌ្ឍជំនាញវិជ្ជាជីវៈ និង ចំណេះដឹងដល់មេធាវីវ័យក្មេង<br>- ការតស៊ូមតិសម្រាប់លក្ខខណ្ឌការអនុវត្តវិជ្ជាជីវៈកាន់តែប្រសើរឡើងសម្រាប់មេធាវីវ័យក្មេង |

| | |
|---|---|
| | - រៀបចំវេទិកា និងកិច្ចពិភាក្សាលើបញ្ហាផ្លូវច្បាប់ និងផលប្រយោជន៍សាធារណៈ<br>- បង្កើតក្រុមការងារមេធាវីវ័យក្មេង និងគណៈកម្មាធិការលើវិស័យប្រកបវិជ្ជាជីវៈ<br>- លើកសំណើ និងអនុសាសន៍ក្នុងការកែទម្រង់ច្បាប់<br>- ផ្តល់អន្តរាគមន៍ផ្នែកច្បាប់ ការអត្ថាធិប្បាយ និងជំនួយលើសិទ្ធិមនុស្ស សេរីភាព រដ្ឋធម្មនុញ្ញ និងបញ្ហាផលប្រយោជន៍សាធារណៈ |
| សិង្ហបុរី | - គណៈកម្មាធិការមេធាវីវ័យក្មេង<br>- បោះផ្សាយកាសែតពិសេសបន្ថែម<br>- បង្កើត Law Society Mentorship Scheme<br>- ការគាំទ្រផ្នែកហិរញ្ញវត្ថុ ដូចជាផ្តល់អាហារូបករណ៍ដើម្បីចូលរួមសន្និសីទអន្តរជាតិជាដើម |
| កូរ៉េខាងត្បូង | - គណៈកម្មាធិការពិសេសសម្រាប់មេធាវីវ័យក្មេង<br>- មជ្ឈមណ្ឌលគាំទ្រមេធាវីវ័យក្មេង<br>- គណៈកម្មាធិការអចិន្ត្រៃយ៍នៃមជ្ឈមណ្ឌលគាំពារមេធាវីវ័យក្មេង<br>- ការបណ្តុះបណ្តាល<br>- ការស្រង់មតិនិងការស្រាវជ្រាវលើស្ថានភាពបច្ចុប្បន្នរបស់មេធាវីវ័យក្មេង<br>- ការផ្តល់ពានរង្វាន់ |
| ជប៉ុន | - ពានរង្វាន់មេធាវីប្រចាំឆ្នាំ<br>- ជាសមាជិកនៃ AIJA (International Association of Young Lawyers)<br>- ក្រុមមេធាវីវ័យក្មេង<br>- កម្មវិធី Mentorship |
| IBA | - គណៈកម្មាធិការមេធាវីវ័យក្មេង |

| | |
|---|---|
| | - វគ្គបណ្តុះបណ្តាលមេធាវីវ័យក្មេង<br>- អ្នកតំណាងថ្នាក់ជាតិ របស់គណៈកម្មាធិការមេធាវីវ័យក្មេង<br>- ពានរង្វាន់មេធាវីវ័យក្មេង |

## ១.១១- លទ្ធផលនៃការស្ទង់មតិមេធាវីវ័យក្មេងនៅកម្ពុជា

ដើម្បីឱ្យកាន់តែទទួលបានទិន្នន័យជាក់លាក់ អនុវត្តតាមអនុសាសន៍ឯកឧត្តម លី ច័ន្ទតុលា ក្រុមការងាររៀបចំគោលនយោបាយមេធាវីវ័យក្មេងបានចងក្រងកម្រងសំណួរ និងធ្វើការស្ទង់មតិមេធាវីវ័យក្មេងនៅកម្ពុជាដើម្បីជាមូលដ្ឋានសម្រាប់កសាងគោលនយោបាយដែលឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងរបស់មេធាវីវ័យក្មេង និងតថភាពសង្គមជាក់ស្តែង។

| បញ្ហាប្រឈម | ចម្លើយ |
|---|---|
| ចំណេះដឹងផ្នែកច្បាប់ | - ច្បាប់ពាណិជ្ជកម្ម (ច្រើនជាងគេ)<br>• កម្មសិទ្ធិបញ្ញា<br>• បរធនបាលកិច្ច<br>• ប្រតិបត្តិការដែលមានកិច្ចធានា<br>• កិច្ចការពារអ្នកប្រើប្រាស់<br>• សារពើពន្ធ<br>• ការចុះបញ្ជីផ្សេងៗ<br>• ពាណិជ្ជកម្មអេឡិចត្រូនិច<br>• ក្ស័យធន<br>• ធនាគារ<br>• វិនិយោគ<br>• ការប្រកួតប្រជែងមិនស្មោះត្រង់ និងពាណិជ្ជនាម<br>- ច្បាប់ការងារ<br>- ច្បាប់ភូមិបាល |

DRAFT

| | |
|---|---|
| | - ច្បាប់សំណង់<br>- ច្បាប់ពាក់ព័ន្ធនឹង ASEAN និង APEC<br>- ច្បាប់ស្តីពីគ្រឿងញៀន |
| ចំណេះដឹងព័ត៌មានវិទ្យា | - ខ្សោយភាសាអង់គ្លេស ពិបាកតាមដានវិធីប្រើបច្ចេកវិទ្យាថ្មី<br>- ប្រឈមនឹងការលួចចូលមើលទិន្នន័យពី Hacker<br>- មិនស្គាល់ AI |
| ទីផ្សារការងារ | - ពិបាករកការងារ ទីផ្សារនិងឱកាសការងារតិច និងចំណូលតិច<br>- មានការប្រកួតប្រជែងទីផ្សារច្រើន (មេធាវីច្រើន ទម្លាក់ថ្លៃសេវា)<br>- ពិបាករកអតិថិជនថ្មី ព្រោះមិនអាចផ្សព្វផ្សាយពាណិជ្ជកម្ម<br>- ទើបចូលប្រកប មិនសូវមានអ្នកស្គាល់ ខ្វះទំនាក់ទំនង<br>- មេធាវីក្មេង មិនសូវត្រូវបានគេឱ្យតម្លៃ និងមិនសូវទុកចិត្ត<br>- មិនទទួលរឿងក្តីដែលមិនត្រូវជំនាញ នាំឱ្យមិនសូវមានការងារ<br>- ការផ្សព្វផ្សាយសេវាឥតគិតថ្លៃនាំឱ្យមិនសូវមានអតិថិជន<br>- កូនក្តីទាមទារតម្រូវការខ្ពស់ តែកម្រៃទាប មិនសមនឹងទំហំការងារ<br>- កូនក្តីទាមទារឱ្យធានាលទ្ធផល ទោះពន្យល់ក៏មិនទទួលយក<br>- កូនក្តីមកពិភាក្សា តែមិនពឹងពាក់ ជ្រែតម្លៃ<br>- វិសមភាពរវាងការងារជាមេធាវី និងភ្នាក់ងារពន្ធដារនាំឱ្យបាត់ឱកាសការងារ<br>- មានបុគ្គលដែលមិនមែនជាមេធាវី ធ្វើកិច្ចការមេធាវី ដូចជាមន្ត្រីតុលាការ មន្ត្រីនគរបាលជាដើម<br>- មានមេធាវីបរទេសបើកដំណើរការច្រើនតាមរយៈការសហការជាមួយមេធាវីក្នុងស្រុកនាំឱ្យមេធាវីវ័យក្មេងមិនមានឱកាសកាន់ការងារធំៗ |
| ជាមួយអតិថិជន | - ទីផ្សារសេរី បន្ទាបតម្លៃ<br>- កូនក្តីមិនបង់ប្រាក់ |

| | |
|---|---|
| | - អតិថិជនទាមទារលើសកំណត់ច្បាប់<br>- អតិថិជនបាត់ទំនុកចិត្ត មកពីមេធាវីមិនធ្វើតាមក្រមសីលធម៌ បង្កើតកំហុសវិជ្ជាជីវៈនាំឱ្យមេធាវីក្រោយពិបាកធ្វើការ<br>- អតិថិជនមិនសូវទុកចិត្តមេធាវីក្មេង<br>- អតិថិជនសួរហើយ មិនពឹងពាក់ ទុករហូតដល់សង្គ្រោះមិនបាន ទើបត្រឡប់មកវិញ<br>- អតិថិជនមិនផ្តោតលើសមត្ថភាព ប៉ុន្តែលទ្ធផល ទាមទារឱ្យធានាលទ្ធផល |
| មេធាវីនិងមេធាវី | - ការមិនឱ្យតម្លៃមេធាវីវ័យក្មេង<br>- មេធាវីវ័យក្មេងប្រកាន់ជំហររឹងមាំ មិនសូវបត់បែន មិនសូវទន់ភ្លន់<br>- មេធាវីក្រោយ និយាយបង្អាប់មេធាវីមុនទៅកូនក្តីនៅពេលដែលចាញ់ក្តី<br>- មេធាវីខ្លះមិនសហការដោះស្រាយទេ បង្កើតរឿង<br>- មេធាវីចាស់ៗផ្តល់យោបល់ ពន្យល់ និងប្រាស្រ័យទាក់ទងល្អ មេធាវីក្មេងៗអាចពិបាក<br>- មេធាវីមួយចំនួនមិនការពារតម្លៃវិជ្ជាជីវៈ ដូចជាមិនបានពិនិត្យសំណុំរឿង ភស្តុតាង ពន្យារពេលនីតិវិធី មិនស្មោះត្រង់ក្នុងការតតាំង |
| ជាមួយស្ថាប័នផ្សេង | - មិនសូវយកចិត្តទុកដាក់គិតថាក្មេង<br>- ពិបាកសុំកម្មវិធី<br>- ប្រើប្រាស់តួនាទីមិនត្រឹមត្រូវ<br>- ពិបាកសុំថតចម្លងសំណុំរឿង (យឺតយ៉ាវឯកសារមិនគ្រប់ជាដើម)<br>- មិនគោរពពេលវេលា<br>- អូសបន្លាយនីតិវិធី<br>- ការបញ្ជូនលិខិតយឺតយ៉ាវ ធ្វើឱ្យខូចប្រយោជន៍កូនក្តី<br>- មិនឱ្យតម្លៃមេធាវី |

DRAFT

| | |
|---|---|
| | - ខ្វះការយល់ដឹងពីសិទ្ធិរបស់មេធាវី (មេធាវីការពារបានតែក្នុងតុលាការជាដើម)<br>- ពិបាកតាមឯកសារនៅសុរិយោដី<br>- ពិបាកធ្វើការជាមួយប៉ូលីសជាដើម (មិនឱ្យថតសំណុំរឿង មិនអនុញ្ញាតឱ្យជួបកូនក្ដីជាដើម) |
| ការធ្វើកម្មសិក្សា | - លំបាកក្នុងការស្វែងរកសំណុំរឿងរដ្ឋប្បវេណី<br>- គ្រូកម្មសិក្សារវល់មិនសូវបានណែនាំ<br>- គេមិនសូវឱ្យតម្លៃ<br>- បង់ប្រាក់ឱ្យការិយាល័យ<br>- មិនសូវមានរឿងក្ដី មិនសូវមានចំណូល<br>- ពិបាកធ្វើរបាយការណ៍កម្មសិក្សា<br>- ស្ថាប័នផ្សេងៗ មិនសូវស្វាគមន៍ ឬឱ្យតម្លៃ ព្រោះនៅកម្មសិក្សា<br>- គ្រូកម្មសិក្សាឱ្យសិស្សចំណាយផ្ទាល់ខ្លួន ដើម្បីតាមដានក្ដីហើយមិនសង |
| បញ្ហាផ្សេងៗ | - ប្រជាជនមិនសូវស្គាល់មេធាវី<br>- នីតិវិធីជាប់គាំង បើគ្មានសេវាជម្រុញ<br>- ខ្វះខាតចំណេះដឹង<br>- មិនសូវមានអតិថិជន<br>- ពិបាកធ្វើការជាមួយស្ថាប័នដទៃ គេមិនសូវឱ្យតម្លៃ<br>- មេធាវីមួយចំនួនបង្កើតភស្តុតាង និងអង្គហេតុជំនួសកូនក្ដី<br>- ការតំណាងឱ្យកូនក្ដីនៅស្ថាប័នផ្សេងក្រៅពីតុលាការអាចត្រូវបានបដិសេធ<br>- ទីផ្សារការងារទាប (មេធាវីខ្លះយកសេវាទាបជ្រុល ប្រថាប់ត្រាកិច្ចសន្យា ត្រឹម ៥០ ដុល្លារជាដើម) |

សំណូមពរ៖

- គួរបើកវគ្គបណ្តុះបណ្តាលបន្ថែម
    - វគ្គសុក្រឹតការ (រៀបចំកម្មវិធីសិក្សាឱ្យស្របទៅនឹងមុខវិជ្ជា)
    - សិក្ខាសាលា Online
    - Exchange Program
- ជួយរកទីផ្សារការងារ និងឱកាសការងារបន្ថែម
- ពិចារណាអំពីសេរីភាព និងភាពច្នៃប្រឌិតក្នុងការផ្សព្វផ្សាយពាណិជ្ជកម្ម
- បន្ធូរបន្ថយការបង់ថវិកាផ្សេងៗ
    - លើកលែងការបង់ភាគទាន ២ ឆ្នាំ
    - លើកលែងការបង់ Office ១ ឆ្នាំ
- បង្កើតក្រុមការងារឆ្លើយតបពិសេសសម្រាប់មេធាវីវ័យក្មេង
- សុំឱ្យគណៈមេធាវីសម្របសម្រួលការងារជាមួយស្ថាប័នផ្សេងៗ
- ផ្សព្វផ្សាយវិជ្ជាជីវៈមេធាវីឱ្យបានទូលំទូលាយ ក្នុងលក្ខណៈជារួម មិនមែនឯកជន
- កំណត់តម្លៃសេវាមេធាវី (កំណត់តម្លៃអប្បរមា)
- ពង្រឹងក្រមសីលធម៌មេធាវី និងការអនុវត្តវិជ្ជាជីវៈ ព្រមទាំងយន្តការពិនិត្យតាមដាននឹងអនុវត្ត
- បង្កើតវេទិកា Networking ឱ្យមេធាវីវ័យក្មេងអាចបង្កើនទំនាក់ទំនង
- ពង្រឹងគ្រូកម្មសិក្សា

## ២- ចក្ខុវិស័យ

ចក្ខុវិស័យនៃគោលនយោបាយនេះគឺ **រួមគ្នាកសាងគ្រឹះនិងត្រួសត្រាយផ្លូវដល់មេធាវីវ័យក្មេងដើម្បីនិរន្តរភាពនៃឧត្តមភាពនិងកិត្យានុភាពនៃវិជ្ជាជីវៈមេធាវី** ។

## ៣- គោលបំណង

គោលបំណងនៃគោលនយោបាយនេះគឺ **រួមចំណែកបម្រើសង្គមជាតិដោយផ្អែកលើច្បាប់និងវិធានវិជ្ជាជីវៈជាធរមាន តាមរយៈការកសាងប្រព័ន្ធអេកូឡូស៊ីដើម្បីគាំទ្រដល់ការប្រកបវិជ្ជាជីវៈ បង្កើនកាលានុវត្តភាពនិងឧត្តមភាពប្រកួតប្រជែងរបស់មេធាវីវ័យក្មេង។**

DRAFT

## ៤- ការវិភាគភាពខ្លាំង ភាពខ្សោយ កាលានុវត្តភាព និងការគំរាមគំហែង

ការវិភាគ SWOT គឺសំដៅទៅការវិភាគភាពខ្លាំង ភាពខ្សោយ ឱកាស និងការគំរាមគំហែង ដែលអនុញ្ញាតឱ្យស្ថាប័នអាចស្វែងយល់ទាំងកត្តាផ្ទៃក្នុង និងខាងក្រៅ ដើម្បីកសាងយុទ្ធសាស្ត្រនិងផែនការសកម្មភាពដើម្បីសម្រេចឱ្យបាននូវចក្ខុវិស័យ និងគោលបំណងនៃគោលនយោបាយមេធាវីវ័យក្មេង។

### ៤.១- <u>ភាពខ្លាំង</u>

- ថ្នាក់ដឹកនាំគណៈមេធាវីក្រោមការដឹកនាំរបស់ ឯកឧត្តម លី ច័ន្ទតុលា ប្រធានគណៈមេធាវី មានឆន្ទៈខ្ពស់ក្នុងការជួយមេធាវីវ័យក្មេងជម្នះឧបសគ្គ បញ្ហាប្រឈមនានាដែលមាននៅពេលចាប់ផ្តើមប្រកបវិជ្ជាជីវៈលើកដំបូងឱ្យទទួលបានជោគជ័យ។
- គណៈមេធាវីមានទីស្នាក់ការធំទូលាយ ដែលបង្កលក្ខណៈនិងផ្តល់លទ្ធភាពក្នុងការអនុវត្តសកម្មភាពនានា នៅទីស្នាក់ការគណៈមេធាវីផ្ទាល់ដោយពុំចាំបាច់ក្នុងការបង្កើនការចំណាយច្រើន ព្រមទាំងមានបណ្ណាល័យ ស្ទូឌីយ៉ូសម្រាប់ការសិក្សាស្រាវជ្រាវ និងថតកិច្ចពិភាក្សាផ្សព្វផ្សាយផ្សេងៗ។
- គណៈមេធាវីត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៩៥ ដែលមានអាយុ ២៩ ឆ្នាំគិតត្រឹមឆ្នាំ២០២៤នេះ។ ក្នុងរយៈពេលជិត ៣ ទសវត្សនេះ គណៈមេធាវីបានឆ្លងកាត់ជាច្រើនដំណាក់កាល និងជម្នះឧបសគ្គជាច្រើនដែលនាំឱ្យគណៈមេធាវីមានទីស្នាក់ការធំទូលាយ និងរចនាសម្ព័ន្ធគ្រប់គ្រងរឹងមាំ។ ភាពចាស់ទុំនេះជាធនធានសំខាន់មួយរបស់គណៈមេធាវីក្នុងការសម្រេចនូវគោលនយោបាយថ្មីៗ ដោយផ្អែកលើបទពិសោធន៍ និងរបៀបរបបការងារដែលមានស្រាប់។
- គិតត្រឹមឆ្នាំ២០២៣ គណៈមេធាវីមានសមាជិកមេធាវី ៣០០៣នាក់ ដែលក្នុងចំនួននេះ មេធាវីពេញសិទ្ធិកំពុងប្រកបវិជ្ជាជីវៈមេធាវីមានចំនួនតែ ២ ៤៧៨នាក់។ ក្រៅពីចំនួនច្រើន សមាជិកគណៈមេធាវីមានភាពចម្រុះលើឯកទេស ជំនាញ និងបទពិសោធន៍។ សមាជិកគណៈមេធាវីដែលពុំប្រកបវិជ្ជាជីវៈជាច្រើនមាន តួនាទីជាថ្នាក់ដឹកនាំនៅក្នុងជួររាជរដ្ឋាភិបាលរួមមាន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការជាដើម។ សមាជិកគណៈមេធាវីដែលកំពុងប្រកបវិជ្ជាជីវៈជាច្រើនក៏ទទួលបានការទុកចិត្តពីរាជរដ្ឋាភិបាលនិងរដ្ឋសភា រហូតទទួលបានការតែងតាំងជាទីប្រឹក្សាជាដើម។

DRAFT

ភាពចម្រុះទាំងអស់នេះស បញ្ជាក់ពីសមត្ថភាព និងការទទួលស្គាល់ពីសង្គមលើវិជ្ជាជីវៈមេធាវី ដែលជាធនធានសំខាន់ក្នុងការ ចូលរួមគាំទ្រ និងអនុវត្តគោលនយោបាយនានា។

- គណៈមេធាវីមានដៃគូជាច្រើនទាំងក្នុងស្រុក និងនៅបរទេស តាមរយៈការចុះអនុស្សរណៈយោគយល់បង្កើតកិច្ចសហប្រតិបត្តិការផ្លូវការ។ នៅក្នុងស្រុករួមមាន ក្រសួងយុត្តិធម៌ ក្រុមប្រឹក្សាជាតិដើម្បីស្ត្រីកម្ពុជា សាកលវិទ្យាល័យជាតិបាត់ដំបង និងស្ថាប័នជាច្រើនទៀត។ នៅបរទេសរួមមាន មជ្ឈមណ្ឌលស្រាវជ្រាវច្បាប់ចិនអាស៊ាន គណៈមេធាវីកូរ៉េខាងត្បូង គណៈមេធាវីឥណ្ឌា និងគណៈមេធាវីបារាំងជាដើម។ ភាពជាដៃគូនេះនឹងរួមចំណែកយ៉ាងខ្លាំងក្នុងការពង្រីកវិសាលភាព ព្រមទាំងកាលានុវត្តភាពក្នុងការគាំទ្រដល់មេធាវីវ័យក្មេង។

## ៤.២- <u>ភាពខ្សោយ</u>

- ធនធាននៅគណៈមេធាវីនៅមានកម្រិតនៅឡើយ ទាំងនេះដោយហេតុថាបន្ទុកចំណាយច្រើន រីឯចំណូលនៅមានកម្រិតព្រោះសមាជិកជាច្រើនពុំបានបង់ភាគទានប្រចាំឆ្នាំទៀងទាត់។ លើសពីនេះការរៀបចំកម្មវិធីសិក្ខាសាលា ការថតវីដេអូផ្សព្វផ្សាយរបស់គណៈមេធាវីទាំងអស់ត្រូវបានធ្វើឡើងដោយឥតគិតថ្លៃជូនចំពោះសមាជិកទាំងអស់ ដែលជាហេតុមួយនាំឱ្យប្រភពចំណូលរបស់គណៈមេធាវីនៅមានកម្រិត។
- បច្ចុប្បន្នយន្តការដែលជួយមេធាវីគឺលក្ខខណ្ឌតម្រូវឱ្យមានគ្រូបង្គោលក្នុងពេលធ្វើកម្មសិក្សា និងការជួបសំណេះសំណាលពីថ្នាក់ដឹកនាំជាមួយមេធាវីទើបចេញប្រកបវិជ្ជាជីវៈ។ ទោះបីជាមានកិច្ចខិតខំប្រឹងប្រែងទាំងនេះក្ដី នៅពុំទាន់មានអង្គភាពទទួលបន្ទុកកិច្ចការមេធាវីវ័យក្មេង ដើម្បីដឹកនាំ សម្របសម្រួលកិច្ចការនេះជាមួយអង្គភាព និងស្ថាប័នពាក់ព័ន្ធនៅឡើយ ដែលនាំឱ្យឧបសគ្គ និងបញ្ហាដែលប្រឈមដោយមេធាវីវ័យក្មេងត្រូវការកិច្ចខិតខំប្រឹងប្រែងបន្ថែមទៀតដើម្បីដោះស្រាយ។
- បច្ចុប្បន្ននៅគណៈមេធាវីមានបណ្ណាល័យ និងគេហទំព័រដែលផ្ទុកសៀវភៅ ទម្រង់គំរូ និងច្បាប់នានា ប៉ុន្តែថ្នាលទាំងនេះពុំទាន់ត្រូវបានប្រើប្រាស់ឱ្យបានទូលំទូលាយនៅឡើយ និងបណ្តុំចំណេះដឹង ជំនាញ ឯកសារ ទម្រង់គំរូដែលចាំបាច់សម្រាប់ការជួយមេធាវីវ័យក្មេងក្នុងការប្រកបវិជ្ជាជីវៈ ក៏ដូចជាដំណើរការការិយាល័យមេធាវីជាដើមនៅមានកម្រិត ដែលចាំបាច់តម្រូវឱ្យមានការបង្កើនការចងក្រងបណ្តុំឯកសារទាំងនេះ និងបង្កើនប្រសិទ្ធភាពនៃថ្នាលផ្ទុកឯកសារឱ្យកាន់តែទទួលបានការប្រើប្រាស់កាន់តែទូលំទូលាយ។

- គណៈមេធាវី ក៏ដូចជាមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវីបានខិតខំប្រឹងប្រែងយ៉ាងខ្លាំងក្នុងការបណ្តុះបណ្តាល និងផ្សព្វផ្សាយច្បាប់តាមរយៈការអភិវឌ្ឍកម្មវិធីសិក្សា សិក្ខាសាលា កម្មវិធី៣សំណួរ វេទិកាមេធាវីជាដើម។ ទោះជាយ៉ាងនេះក្តីមេធាវីវ័យក្មេងមានតម្រូវបន្ថែមលើការបណ្តុះបណ្តាលជំនាញច្បាប់រួមមាន ភាពជាអ្នកដឹកនាំ ការចរចា ការដំណើរការការិយាល័យមេធាវី ការគ្រប់គ្រងហិរញ្ញវត្ថុជាដើម។ ជំនាញនិងចំណេះដឹងក្រៅពីច្បាប់តម្រូវឱ្យគណៈមេធាវី និងអង្គភាពពាក់ព័ន្ធស្វែងរកមធ្យោបាយដើម្បីឆ្លើយតប ក៏ដូចជាជួយមេធាវីវ័យក្មេងឱ្យមានចំណេះដឹងនិងជំនាញបន្ថែមដើម្បីជម្នះរាល់ឧបសគ្គ និងបញ្ហាប្រឈមក្នុងការប្រកបវិជ្ជាជីវៈមេធាវីលើកដំបូង។
- គណៈមេធាវី ក៏ដូចជាមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវីបានខិតខំប្រឹងប្រែងជាប្រចាំ ដើម្បីអភិវឌ្ឍកម្មវិធីបណ្តុះបណ្តាល ក៏ដូចជាបង្កើនគុណភាពនៃការបណ្តុះបណ្តាលតាមរយៈការពង្រឹង ការជ្រើសរើសសិស្សមេធាវី រៀបចំឱ្យមានការបោះជំរុំសិស្សមេធាវីដើម្បីស្វែងយល់អំពីការអនុវត្តជាក់ស្តែងជាមួយអាជ្ញាធរពាក់ព័ន្ធ និងការជ្រើសរើសគ្រូបណ្តុះបណ្តាលដែលពោរពេញដោយបទពិសោធន៍ និងចំណេះដឹងជាដើម។ ទោះជាយ៉ាងណាក៏ដោយ ការវិវឌ្ឍដ៏លឿនរបស់ច្បាប់ សង្គម និងសេដ្ឋកិច្ចកំណើននៃការប្រកួតប្រជែងនៅក្នុងប្រទេស និងពីបរទេស តម្រូវឱ្យគណៈមេធាវី ក៏ដូចជាមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវីប្រឹងប្រែងបន្ថែមទៀតដើម្បីពង្រឹងគុណភាពបណ្តុះបណ្តាលឱ្យឆ្លើយតបទៅនឹងការវិវឌ្ឍថ្មីៗ។

## ៤.៣- <u>កាលានុវត្តភាព</u>

- យោងតាមកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលនីតិកាលទី៧នៃរដ្ឋសភា សម្រាប់ការកសាង និងការការពារមាតុភូមិឆ្នាំ២០២៣-២០២៨ ចំណុចសំខាន់ៗដែលគណៈមេធាវីនិងមេធាវីអាចចូលរួមចំណែកបានរួមមាន គោលដៅយុទ្ធសាស្ត្រពាក់ព័ន្ធនឹងការកសាងសង្គមដោយផ្អែកលើច្បាប់ សេដ្ឋកិច្ចរីកចម្រើន សុខដុមរមនា និងគោរពសិទ្ធិមនុស្ស។ រីឯគោលនយោបាយធំៗជាអាទិភាពដែលពាក់ព័ន្ធ រួមមានការលើកកម្ពស់ជីវភាពប្រជាជនគ្រប់រូប ទាំងខាងសម្ភារនិងស្មារតីឱ្យបានសមរម្យប្រកបដោយ ភាពថ្លៃថ្នូរ និងការលើកស្ទួយលទ្ធិប្រជាធិបតេយ្យ សិទ្ធិសេរីភាពប្រជាជន និងពង្រឹងនីតិរដ្ឋ ក៏ត្រូវការមេធាវីឱ្យចូលរួមដើម្បីសម្រេចបាននូវគោលដៅនោះដែរ។ ដូចគ្នានេះដែរ ចំពោះគោលនយោបាយអភិវឌ្ឍតាមវិស័យ រួមមាន ការធ្វើពិពិធកម្មសេដ្ឋកិច្ច ការជំរុញការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធឌីជីថល ការជំរុញឌីជីថ-លូបនីយកម្មសេដ្ឋកិច្ចនិងសង្គម ការជំរុញពាណិជ្ជកម្មអន្តរជាតិ និងការអភិវឌ្ឍវិស័យឯកជន សុទ្ធតែ

ទាមទារការចូលរួមចំណែករបស់មេធាវី ដែលតម្រូវឱ្យមេធាវីវ័យក្មេងមានសមត្ថភាពចាំបាច់ ក្នុងការចូលរួមចំណែកនៅក្នុងកម្មវិធីនយោបាយខាងលើ។

- យោងតាមរបាយការណ៍របស់ធនាគារអភិវឌ្ឍអាស៊ីបង្ហាញឱ្យឃើញថានៅឆ្នាំ២០២៣ កម្ពុជាមានកំណើនសេដ្ឋកិច្ច ៥,៣% និងរំពឹងថាមានកំណើន ៦% នៅឆ្នាំ២០២៤។[5] លើសពីនេះ សន្ទុះនៃការវិនិយោគនៅកម្ពុជាត្រូវបានព្យាករថាមានចំណាត់ថ្នាក់លេខ១ផងដែរនៅឆ្នាំ២០២៤[6] ប្រៀបធៀបនឹងប្រទេសដទៃទៀត។ ការរីកចម្រើនគ្រប់វិស័យនេះគឺដោយសារគោលនយោបាយដែលដាក់ចេញដោយរាជរដ្ឋាភិបាលអាណត្តិទី៧ និងការផ្ទេរអំណាចប្រកបដោយសន្តិភាព និងស្ថិរភាព ដែលជាកត្តាចាំបាច់បំផុតទាក់ទាញវិនិយោគិនបរទេស និងបង្កើនបរិយាកាសធុរកិច្ចនៅកម្ពុជាកាន់តែប្រសើរ។ ការរីកចម្រើនលើគ្រប់វិស័យនេះនាំមកនូវកាលានុវត្តភាពថ្មីៗជាច្រើនដល់មេធាវីវ័យក្មេង ដែលចាំបាច់ត្រូវមានសមត្ថភាព ឧបករណ៍ និងការគាំទ្រចាំបាច់នានាដើម្បីចាប់យកកាលានុវត្តទាំងអស់នេះ។
- មេធាវីកម្ពុជាត្រូវបានសង្កេតឃើញថាភាគច្រើនបំផុតផ្តល់សេវាផ្នែកច្បាប់នៅក្នុងប្រទេសកម្ពុជា ចំណែកការផ្តល់សេវាផ្នែកច្បាប់នៅបរទេសពុំទាន់ត្រូវបានសង្កេតឃើញថាត្រូវបានផ្តល់ច្រើននៅឡើយ។ យោងតាមរបាយការណ៍របស់គណៈមេធាវីអន្តរជាតិ[7] ប្រទេសដែលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោកស្ទើរតែទាំងអស់អនុញ្ញាតឱ្យមេធាវីបរទេសផ្តល់សេវាផ្នែកច្បាប់នៅប្រទេសរបស់ខ្លួន រួមមានសន្ធានកម្មមជ្ឈត្តការ និងការប្រឹក្សាយោបល់លើច្បាប់បរទេស និងអន្តរជាតិជាដើម លើកលែងតែការតំណាងនៅតុលាការ និងប្រឹក្សាយោបល់ច្បាប់នៃប្រទេសនោះ។ ទាំងនេះបង្ហាញឱ្យឃើញពីសក្តានុពលដ៏ធំធេងសម្រាប់មេធាវីកម្ពុជាដែលពុំទាន់ត្រូវបានប្រើប្រាស់ឱ្យអស់ពីលទ្ធភាពនៅឡើយ។ ហេតុនេះចាំបាច់ឱ្យមានយន្តការ និងមធ្យោបាយនានាដើម្បីលើកកម្ពស់មេធាវីកម្ពុជាផ្តល់សេវាផ្នែកច្បាប់នៅបរទេស។
- ការផ្តល់សេវាផ្នែកច្បាប់ដែលពាក់ព័ន្ធនឹងច្បាប់អន្តរជាតិ ការដោះស្រាយវិវាទ និងប្រតិបត្តិការដែលស្មុគស្មាញនិងមានទំហំធំនៅកម្ពុជាត្រូវបានសង្កេតឃើញថាត្រូវបានផ្តល់ដោយមេធាវីបរទេស ឬដោះ

---

[5] https://www.adb.org/news/adb-adjusts-2023-growth-forecast-cambodia-maintains-2024-outlook#:~:text=PHNOM%20PENH%2C%20CAMBODIA%20(20%20September,flagship%20economic%20report%20launched%20today.

[6] https://www.fdiintelligence.com/content/feature/cambodia-carries-the-strongest-fdi-momentum-into-2024-83236

[7] https://www.ibanet.org/BIC-ITILS/The-Regulation-of-International-Legal-Services

ស្រាយនៅប្រទេសសិង្ហបុរី ហុងកុងជាដើម។ កត្តាទាំងនេះជាការបាត់បង់ប្រភពចំណូលដ៏ធំ និងជាសក្តានុពលទីផ្សារសេវាផ្នែកច្បាប់ដែលមេធាវីកម្ពុជាត្រូវប្រើប្រាស់ឱ្យអស់ពីលទ្ធភាព។ ហេតុនេះកាលានុវត្តភាពសម្រាប់ទីផ្សារសេវាផ្នែកច្បាប់នៅក្នុងស្រុកនៅមានជាច្រើន ដែលចាំបាច់ត្រូវមានមធ្យោបាយសម្រាប់មេធាវីទាញយកកាលានុវត្តទាំងអស់នេះ។

## ៤.៤- ការគំរាមគំហែង

- ការបង្កើតវិជ្ជាជីវៈថ្មីៗនៅកម្ពុជាមួយចំនួនបានបង្កើនកាលានុវត្តភាពដល់មេធាវី ហើយមួយចំនួនក៏បង្កើនការប្រកួតប្រជែងដល់វិជ្ជាជីវៈមេធាវីផងដែរ។ លើសពីនេះក៏មានកំណើននៃការប្រើប្រាស់សេវាផ្សេងៗជំនួសឱ្យសេវាផ្នែកច្បាប់ ដែលពុំទាន់មានបទប្បញ្ញត្តិជាក់លាក់គ្រប់គ្រងនៅឡើយ ដូចជាការប្រឹក្សាយោបល់លើកិច្ចសន្យាអចលនវត្ថុពីសំណាក់ភ្នាក់ងារអចលនទ្រព្យជាជាងមេធាវីជាដើម។ បន្ថែមលើនេះកំណើននៃទីផ្សារសេរីក៏បើកឱកាសឱ្យមេធាវីបរទេសពង្រីកការផ្តល់សេវារបស់ខ្លួននៅកម្ពុជាផងដែរ។ កំណើននៃការប្រកួតប្រជែងទាំងនេះតម្រូវឱ្យមានយន្តការជាក់លាក់ដើម្បីធានាមេធាវីកម្ពុជា មានសមត្ថភាពប្រកួតប្រជែង និងរក្សាទំហំទីផ្សារសេវាផ្នែកច្បាប់សម្រាប់មេធាវីកម្ពុជា។
- ដោយហេតុប្រទេសកម្ពុជាជាប្រទេសតូចនិងកំពុងអភិវឌ្ឍន៍ ដែលស្ថិតក្នុងការប្រកួតប្រជែងរវាងប្រទេសមហាអំណាចក្នុងបរិបទភូមិសាស្ត្រនយោបាយនាពេលបច្ចុប្បន្ន ធ្វើឱ្យកម្ពុជារងការវាយប្រហារតាមប្រព័ន្ធសារព័ត៌មានបរទេស ក៏ដូចអង្គការសង្គមស៊ីវិលទទួលជំនួយពីបរទេស ដែលមានចេតនាធ្វើឱ្យមានអស្ថិរភាព និងអាប់ឱនកេរ្តិ៍ឈ្មោះកម្ពុជា ទាំងបំពានគោលការណ៍អធិបតេយ្យភាពរបស់រដ្ឋនីមួយៗដែលមានចែងនៅក្នុងធម្មនុញ្ញអង្គការសហប្រជាជាតិ។ ការប៉ះពាល់ដល់កេរ្តិ៍ឈ្មោះរបស់ប្រទេសជាតិក៏ជះឥទ្ធិពលផងដែរដល់កេរ្តិ៍ឈ្មោះប្រព័ន្ធយុត្តិធម៌ និងមេធាវីនៅកម្ពុជាដែលនាំឱ្យប៉ះពាល់ដល់ជំនឿទុកចិត្តពីសាធារណជន។ កត្តានេះជាការគំរាមគំហែងដល់ កេរ្តិ៍ឈ្មោះវិជ្ជាជីវៈមេធាវីនៅកម្ពុជាដែលចាំបាច់ត្រូវមានមធ្យោបាយឆ្លើយតប ដើម្បីធានានិរន្តរភាព និងទីផ្សារសេវាផ្នែកច្បាប់សម្រាប់មេធាវីកម្ពុជាជាពិសេសមេធាវីវ័យក្មេង។
- ពិភពលោកបច្ចុប្បន្នមានការវិវឌ្ឍក្នុងល្បឿនមួយយ៉ាងលឿនទាំងផ្នែកច្បាប់ បច្ចេកវិទ្យា ពាណិជ្ជកម្ម និងភូមិសាស្ត្រនយោបាយជាដើម។ ច្បាប់ថ្មីៗត្រូវបានអនុម័តឡើងដើម្បីគ្រប់គ្រងបច្ចេកវិទ្យាថ្មីៗដូចជាបញ្ញាសិប្បនិមិត្ត ប្រព័ន្ធបណ្តាញសង្គមយក្ស ពន្ធដារលើពាណិជ្ជកម្មតាមប្រព័ន្ធអនឡាញជាដើម និងបច្ចេកវិទ្យាហិរញ្ញវត្ថុថ្មី រួមទាំងសេវាហិរញ្ញវត្ថុមិនមែនធនាគារជាច្រើនផងដែរ។ ខណៈដែលការវិវឌ្ឍ

នេះបង្កើនកាលានុវត្តភាព តែក៏នាំមកនូវការគំរាមគំហែងផងដែរចំពោះមេធាវី ព្រោះប្រសិនបើមេធាវីមិនបានអភិវឌ្ឍខ្លួនឱ្យទាន់នឹងការវិវឌ្ឍនេះ នោះមេធាវីនឹងបាត់បង់ឱកាសផ្តល់សេវាផ្នែកច្បាប់ជាច្រើន ហើយនឹងធ្លាក់ទៅមេធាវីបរទេសទៅវិញ។ ហេតុនេះតម្រូវឱ្យមានការអភិវឌ្ឍសមត្ថភាពជាប្រចាំ និងមានយន្តការដើម្បីសិក្សាស្រាវជ្រាវឆ្លើយតបទៅនឹងការវិវឌ្ឍទាំងនោះ។

- បច្ចុប្បន្នការផ្តល់បៀវត្ស ក៏ដូចជាឱកាសការងារភាគច្រើនត្រូវបានសង្កេតឃើញថាផ្តោតទៅលើវ័យ។ ចំពោះអ្នកប្រកបវិជ្ជាជីវៈភាគច្រើនទោះបីជាមានសមត្ថភាព តែពុំទទួលបានឱកាសនានាព្រោះអាយុតិច។ ការផ្តល់តម្លៃលើអាយុជាជាងសមត្ថភាពនេះជះឥទ្ធិពលខ្លាំងជាពិសេសលើមេធាវីវ័យក្មេង។ ហេតុនេះចាំបាច់តម្រូវឱ្យមានមធ្យោបាយ និងយន្តការដើម្បីបណ្តុះគំនិតលើកកម្ពស់ការផ្តល់តម្លៃ លើសមត្ថភាព ក៏ដូចជាផ្តល់ឱកាសដើម្បីបញ្ចេញសមត្ថភាពសម្រាប់ការវាយតម្លៃការងារ។
- នៅក្នុងវិជ្ជាជីវៈផ្នែកច្បាប់ ឱកាសការងារភាគច្រើនត្រូវបានផ្តល់ទៅមេធាវីដែលមានបទពិសោធន៍ មានកេរ្តិ៍ឈ្មោះល្បីល្បាញ និងវ័យចំណាស់។ លើសពីនេះថ្នាលផ្លូវការសម្រាប់មេធាវីវ័យក្មេងបញ្ចេញសមត្ថភាពនៅពុំទាន់មាននៅឡើយ។ អាស្រ័យហេតុនេះតម្រូវឱ្យមានមធ្យោបាយ ឬយន្តការដើម្បីឆ្លើយតបទៅនឹងកង្វះឱកាសការងារ និងថ្នាលបញ្ចេញសមត្ថភាពសម្រាប់មេធាវីវ័យក្មេង ដែលជាអនាគតរបស់វិជ្ជាជីវៈមេធាវី។

## ៥- គោលដៅ

ដើម្បីសម្រេចបាននូវចក្ខុវិស័យ និងគោលបំណងខាងលើ គណៈមេធាវីដាក់ចេញនូវគោលដៅ ក្នុងការធានាដល់មេធាវីវ័យក្មេងទទួលបានជោគជ័យនៅក្នុងការប្រកបវិជ្ជាជីវៈមេធាវី ដែលតាមរយៈគោលនយោបាយនេះធានាបាននូវការគាំទ្រនិងពង្រឹងជីវភាព ឱកាស ជំនឿទុកចិត្ត ឧបករណ៍ និងសមត្ថភាពក្នុងការប្រកបវិជ្ជាជីវៈ។

**គោលដៅទី១៖** បង្កើតរចនាសម្ព័ន្ធរឹងមាំដើម្បីគាំទ្រនិងពង្រឹងជីវភាពមេធាវីវ័យក្មេង

**គោលដៅទី២៖** បង្កើនឱកាសការងារកាន់តែច្រើនសម្រាប់មេធាវីវ័យក្មេង

**គោលដៅទី៣៖** បង្កើនជំនឿទុកចិត្តពីសង្គមលើមេធាវីវ័យក្មេង

**គោលដៅទី៤៖** បង្កើតបណ្តុំឧបករណ៍សម្រាប់ជួយដល់ការប្រកបវិជ្ជាជីវៈរបស់មេធាវីវ័យក្មេង

**គោលដៅទី៥៖** បង្កើតយន្តការពង្រឹងសមត្ថភាពមេធាវីវ័យក្មេង

## ៦- យុទ្ធសាស្ត្រ

### គោលដៅទី១៖ បង្កើតរចនាសម្ព័ន្ធរឹងមាំដើម្បីគាំទ្រនិងពង្រឹងជីវភាពមេធាវីវ័យក្មេង

| | |
|---|---|
| **យុទ្ធសាស្ត្រទី១៖** | បង្កើតគណៈកម្មាធិការកិច្ចការមេធាវីវ័យក្មេង |
| **យុទ្ធសាស្ត្រទី២៖** | ពង្រឹងយន្តការដែលមានស្រាប់ |
| **យុទ្ធសាស្ត្រទី៣៖** | បង្កើតយន្តការទ្រទ្រង់ជីវភាពមេធាវីវ័យក្មេង |

### គោលដៅទី២៖ បង្កើនឱកាសការងារកាន់តែច្រើនសម្រាប់មេធាវីវ័យក្មេង

| | |
|---|---|
| **យុទ្ធសាស្ត្រទី១៖** | កសាងភាពជាដៃគូជាមួយភាគីពាក់ព័ន្ធដើម្បីគាំទ្រមេធាវីវ័យក្មេង |
| **យុទ្ធសាស្ត្រទី២៖** | បង្កើនការយល់ដឹងអំពីវិជ្ជាជីវៈមេធាវី |
| **យុទ្ធសាស្ត្រទី៣៖** | បង្កើតវេទិកាមេធាវីវ័យក្មេងនិងភាគីពាក់ព័ន្ធ |

### គោលដៅទី៣៖ បង្កើនជំនឿទុកចិត្តពីសង្គមលើមេធាវីវ័យក្មេង

| | |
|---|---|
| **យុទ្ធសាស្ត្រទី១៖** | បង្កើតពានរង្វាន់មេធាវីវ័យក្មេងប្រចាំឆ្នាំ |
| **យុទ្ធសាស្ត្រទី២៖** | ពង្រឹងការអនុវត្តវិធានវិជ្ជាជីវៈ និងក្រមសីលធម៌ដល់មេធាវីវ័យក្មេង |
| **យុទ្ធសាស្ត្រទី៣៖** | លើកកម្ពស់ការចូលរួមពីមេធាវីវ័យក្មេងដើម្បីផលប្រយោជន៍សាធារណៈ |

### គោលដៅទី៤៖ បង្កើតបណ្តុំឧបករណ៍សម្រាប់ជួយដល់ការប្រកបវិជ្ជាជីវៈរបស់មេធាវីវ័យក្មេង

| | |
|---|---|
| **យុទ្ធសាស្ត្រទី១៖** | កសាងបណ្ណាល័យអេឡិចត្រូនិច |
| **យុទ្ធសាស្ត្រទី២៖** | ចងក្រងទម្រង់ឯកសារគំរូដែលចាំបាច់ក្នុងការប្រកបវិជ្ជាជីវៈ |
| **យុទ្ធសាស្ត្រទី៣៖** | ចងក្រងចំណេះដឹង និងជំនាញដែលចាំបាច់ក្នុងការប្រកបវិជ្ជាជីវៈ |

DRAFT

**គោលដៅទី៥៖ បង្កើតយន្តការពង្រឹងសមត្ថភាពមេធាវីវ័យក្មេង**

| | |
|---|---|
| **យុទ្ធសាស្ត្រទី១៖** | ពង្រឹងគុណភាពនៃការបណ្តុះបណ្តាលផ្ទៃក្នុង |
| **យុទ្ធសាស្ត្រទី២៖** | បណ្តុះបណ្តាលសមត្ថភាពជំនាញវិជ្ជាជីវៈមេធាវីបន្ថែម |
| **យុទ្ធសាស្ត្រទី៣៖** | សហការជាមួយសាកលវិទ្យាល័យដើម្បីពង្រឹងគុណភាពមេធាវីវ័យក្មេងបន្ថែម |

# ៧- ផែនការសកម្មភាព

ផែនការសកម្មភាពលម្អិតមានរៀបរាប់នៅក្នុងតារាងសកម្មភាពនៃផែនការយុទ្ធសាស្ត្រ។

## ៧.១- ការបង្កើតយន្តការ

គោលនយោបាយមេធាវីវ័យក្មេងមិនត្រឹមតែជាឧបករណ៍ដើម្បីជួយមេធាវីវ័យក្មេងឱ្យទទួលបានជោគជ័យក្នុងការប្រកបវិជ្ជាជីវៈមេធាវីប៉ុណ្ណោះទេ តែក៏ជាឧបករណ៍ដើម្បីពង្រីកសក្តានុពលទីផ្សារសេវាផ្នែកច្បាប់ដល់មេធាវីកម្ពុជាទាំងអស់ និងចូលរួមសម្រេចបាននូវចក្ខុវិស័យ និងគោលនយោបាយដែលដាក់ចេញដោយ **ឯកឧត្តម លី ច័ន្ទតុលា** ប្រធានគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ព្រមទាំងបេសកកម្មរបស់គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាដែលកំណត់នៅក្នុងច្បាប់ស្តីពីលក្ខន្តិកៈមេធាវី។ ដើម្បីធានាប្រសិទ្ធភាពនៃការអនុវត្តគោលនយោបាយនេះ យន្តការចំបាច់នឹងត្រូវបង្កើតឡើងរួមមាន៖ គណៈកម្មាការកិច្ចការមេធាវីវ័យក្មេង ព្រមទាំងយន្តការផ្សេងៗទៀតដែលមានកំណត់ នៅក្នុងតារាងផែនការសកម្មភាពដែលនឹងត្រូវដាក់ចេញដាក់ស្តែង។

## ៧.២- ការបង្កើតក្របខ័ណ្ឌគតិយុត្ត

ការអនុវត្តគោលនយោបាយនេះត្រូវអនុលោមតាមច្បាប់ស្តីពីលក្ខន្តិកៈមេធាវី ក្រមសីលធម៌មេធាវី បទបញ្ជាផ្ទៃក្នុងគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា បទដ្ឋានគិតយុត្ត និងវិធានវិជ្ជាជីវៈមេធាវីជាធរមាន។ គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជានឹងចេញសេចក្តីសម្រេចពាក់ព័ន្ធដាក់ស្តែងក្នុងការអនុវត្តគោលនយោបាយនេះ។

DRAFT

## ៧.៣- ការគាំទ្រហិរញ្ញវត្ថុ

ប្រភពធនធានហិរញ្ញវត្ថុសម្រាប់អនុវត្តគោលនយោបាយមេធាវីវ័យក្មេង គឺជាផ្នែកមួយនៃគម្រោងថវិកាប្រចាំឆ្នាំរបស់គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។ ថ្វីត្បិតការអនុវត្តគោលនយោបាយនេះបង្កើនបន្ទុកចំណាយដល់គណៈមេធាវី លទ្ធផលនៃគោលនយោបាយនេះរំពឹងថានឹងចូលរួមបង្កើនចំណូលដល់គណៈមេធាវីដើម្បីធានានិរន្តរភាពក្នុងការផ្តល់សេវាដល់សមាជិក ព្រមទាំងលើកកម្ពស់ការប្រកបវិជ្ជាជីវៈមេធាវីនៅកម្ពុជា តាមរយៈការបង្កើនប្រសិទ្ធភាពនៃការបង់ភាគទានប្រចាំឆ្នាំ ការចូលរួមឧបត្ថម្ភលើកម្មវិធីបណ្តុះបណ្តាលនិងកម្មវិធីសិក្ខាសាលានានាជាដើម ដោយហេតុថាជីវភាពរបស់សមាជិកត្រូវបានបង្កើនតាមរយៈការពង្រីកសក្តានុពលទីផ្សារសេវាផ្នែកច្បាប់ ជំនឿទុកចិត្តលើមេធាវី និងកំណើនសមត្ថភាពរបស់មេធាវីក្នុងការផ្តល់សេវាផ្នែកច្បាប់ប្រកបដោយគុណភាព និងអនុលោមតាមច្បាប់ និងក្រមសីលធម៌វិជ្ជាជីវៈ។ សម្រាប់គម្រោងថវិកាជាក់ស្តែងនឹងត្រូវបានរៀបចំឡើងដោយអង្គភាពទទួលបន្ទុកលើយុទ្ធសាស្ត្រ និងសកម្មភាពនីមួយៗ។

## ៧.៤- ការអភិវឌ្ឍធនធានមនុស្ស

ធនធានមនុស្សគឺជាកម្លាំងស្នូលដើម្បីសម្រេចបានចក្ខុវិស័យ និងអនុវត្តគោលនយោបាយមេធាវីវ័យក្មេងប្រកបដោយប្រសិទ្ធភាព។ ដើម្បីអភិវឌ្ឍធនធានមនុស្សដើម្បីបង្កើនប្រសិទ្ធភាពក្នុងការអនុវត្តគោលនយោបាយ អគ្គលេខាធិការដ្ឋានគណៈមេធាវីនឹងកំណត់បុគ្គលបង្គោលដើម្បីទទួលបានការបណ្តុះបណ្តាលក្នុងនិងក្រៅប្រទេស រួមទាំងទស្សនកិច្ចសិក្សាក្នុងនិងក្រៅប្រទេសដើម្បីដកស្រង់បទពិសោធន៍ និងស្វែងយល់អំពីការគាំទ្រមេធាវីវ័យក្មេងនៅបរទេសជាដើម។ល។

## ៧.៥- ដំណើរការអនុវត្ត

ដំណើរការអនុវត្តនៃគោលនយោបាយនេះមាន៣ដំណាក់កាលគឺ ដំណាក់កាលត្រៀម ដំណាក់កាលចាប់ផ្តើម និងដំណាក់កាលអនុវត្ត។

**ដំណាក់កាលត្រៀម៖** នឹងត្រូវធ្វើឡើងនៅក្នុងត្រីមាសទី៣ នៃឆ្នាំ២០២៤ ដែលរួមមានជំហានដូចតទៅ ១) ការផ្សព្វផ្សាយនិងបែងចែកភារៈកិច្ចដល់បុគ្គលិកគណៈមេធាវីដែលពាក់ព័ន្ធទាំងអស់អំពីគោលដៅ នៃគោលនយោបាយមេធាវីវ័យក្មេង, ២) ការចាប់ផ្តើមប្រតិបត្តិការតាមអង្គភាពទទួលបន្ទុក, ៣) កសាង

DRAFT

ប្រព័ន្ធតាមដានត្រួតពិនិត្យនិងវាយតម្លៃ, ៤) ចេញសេចក្តីសម្រេចបង្កើតអង្គភាពទទួលបន្ទុក និងយន្តការចាំបាច់ក្នុងការអនុវត្តគោលនយោបាយ។

**ដំណាក់កាលចាប់ផ្តើម៖** នឹងត្រូវធ្វើឡើងរហូតដល់ត្រូវដំណាច់ឆ្នាំ២០២៤ ដែលជំហានរៀបចំត្រៀមចាំបាច់ផ្សេងៗទៀតដើម្បីសម្រេចគោលបំណងនៃគោលនយោបាយ។ ជំហានទាំងនោះរួមមាន៖ ១) អនុវត្តជំហានបន្ថែមក្នុងការបែងចែកធនធាន, ២) កសាងធនធានមនុស្ស និងជ្រើសរើសបុគ្គលិក, ៣) កសាងនីតិវិធីនិងរបៀបរបបការងាររបស់អង្គភាព និងយន្តការទើបបង្កើតថ្មី។

**ដំណាក់កាលអនុវត្ត៖** នឹងត្រូវធ្វើឡើងក្នុងរយៈពេលទាំងមូលនៃគោលនយោបាយ ដែលនឹងត្រូវអនុវត្តរាល់សកម្មភាពចាំបាច់ទាំងអស់សំដៅដល់ការគាំទ្រមេធាវីវ័យក្មេង ដើម្បីសម្រេចបាននូវចក្ខុវិស័យ និងគោលបំណងនៃគោលនយោបាយ។

សម្រាប់ដំណាក់កាលអនុវត្តសកម្មភាពអាទិភាព នឹងផ្តោតទៅលើការបង្កើតរចនាសម្ព័ន្ធរឹងមាំដើម្បីគាំទ្រនិងពង្រឹងជីវភាព និងការបង្កើតយន្តការពង្រឹងសមត្ថភាពមេធាវីវ័យក្មេង។

## ៨- ការតាមដានត្រួតពិនិត្យនិងការវាយតម្លៃ

ការត្រួតពិនិត្យលើការអនុវត្តគោលនយោបាយមេធាវីវ័យក្មេង នឹងធ្វើឡើងដោយអង្គភាពទទួលបន្ទុកលើយុទ្ធសាស្ត្រនិងសកម្មភាព ដោយសហការជាមួយអង្គភាពចំណុះគណៈមេធាវីទាំងអស់។ ប្រព័ន្ធតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ នឹងត្រូវបានបង្កើតឡើងសម្រាប់ប្រមូល វិភាគ និងរាយការណ៍អំពីទិន្នន័យ រួមជាមួយនឹងសូចនាករសម្រាប់សកម្មភាពនីមួយៗដែលនឹងត្រូវបង្កើតឡើង។ របាយការណ៍រួមជាមួយអនុសាសន៍នឹងត្រូវដាក់ជូនក្រុមប្រឹក្សាគណៈមេធាវីជារៀងរាល់ ៣ ខែម្តង។

## ៩- សេចក្តីសន្និដ្ឋាន

គោលនយោបាយមេធាវីវ័យក្មេងត្រូវបានរៀបចំឡើងដើម្បីធានាថាអនាគតមេធាវីកម្ពុជា មានសមត្ថភាពច្បាស់លាស់ ឧត្តមភាពប្រកួតប្រជែង ប្រកាន់ខ្ជាប់ក្រមសីលធម៌វិជ្ជាជីវៈ និងចូលរួមបម្រើវិស័យយុត្តិធម៌ សេដ្ឋកិច្ច និងសង្គម។ មេធាវីវ័យក្មេងជាអ្នកធានាឧត្តមភាពនិងកិត្យានុភាពមេធាវីនាពេលអនាគត។ ហេតុនេះក្នុងនាមគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា និងក្នុងនាមជាសមាជិកមេធាវីរៀមច្បង យើងទាំងអស់គ្នាមានកាតព្វកិច្ចក្នុងការត្រួសត្រាយផ្លូវ កសាងគ្រឹះ និងអនាគតមួយប្រកបដោយនិរន្តរភាពសម្រាប់

មេធាវីជំនាន់ក្រោយ។ សមិទ្ធិផលនៃគោលនយោបាយនេះពុំត្រឹមតែផ្តល់ប្រយោជន៍ដល់មេធាវីវ័យក្មេងប៉ុណ្ណោះទេ តែក៏ផ្តល់ផលប្រយោជន៍ដល់សមាជិកគណៈមេធាវីទាំងអស់ តាមរយៈការពង្រីក កាលានុវត្តភាពទីផ្សារសេវាផ្នែកច្បាប់ទាំងក្នុងនិងក្រៅប្រទេស ព្រមទាំងថ្នាលអភិវឌ្ឍន៍សមត្ថភាពវិជ្ជាជីវៈបន្ត និងយន្តការនានាឆ្លើយតបទៅនឹងកំណើននៃការប្រកួតប្រជែង និងការវិវឌ្ឍសង្គមជាតិ និងសកលលោកដែលមានល្បឿនលឿន។ គោលនយោបាយនេះត្រូវបានរៀបចំឡើងដោយពិចារណាគ្រប់ជ្រុងជ្រោយលើស្ថានភាពមេធាវីនាពេលបច្ចុប្បន្ន ភាពខ្លាំង ភាពខ្សោយ កាលានុវត្តភាព និងការគំរាមគំហែង រួមទាំងបញ្ហាប្រឈមនិងការរំពឹងទុករបស់មេធាវីវ័យក្មេងដែលផ្អែកលើលទ្ធផលស្រាវជ្រាវរបស់ស្ថាប័នអន្តរជាតិ និងប្រើប្រាស់មធ្យោបាយជាក់លាក់ក្នុងការកសាងយុទ្ធសាស្ត្រដើម្បីសម្រេចឱ្យបាននូវចក្ខុវិស័យ និងគោលបំណងនៃគោលនយោបាយនេះ។ ក្នុងនោះការបង្កើតយន្តការជាក់លាក់រួមមាន ការបង្កើតគណៈកម្មការកិច្ចការមេធាវីវ័យក្មេង និងយន្តការនានា ដំណាក់កាលអនុវត្តច្បាស់លាស់ និងយន្តការត្រួតពិនិត្យតាមដាននិងវាយតម្លៃជាក់លាក់ និងធានាប្រសិទ្ធិភាពនៃការអនុវត្តគោលនយោបាយមេធាវីវ័យក្មេង។

DRAFT

## តារាងសកម្មភាពនៃក្របខណ្ឌយុទ្ធសាស្ត្រ

| ល.រ | យុទ្ធសាស្ត្រ | សកម្មភាពអាទិភាព | អង្គភាពទទួលបន្ទុក | ផ្សេងៗ |
|---|---|---|---|---|
| **គោលដៅទី១៖ បង្កើតរចនាសម្ព័ន្ធរឹងមាំដើម្បីគាំទ្រនិងពង្រឹងជីវភាពមេធាវីវ័យក្មេង** | | | | |
| ១ | **យុទ្ធសាស្ត្រទី១៖** បង្កើតគណៈកម្មការកិច្ចការមេធាវីវ័យក្មេង | បង្កើតគណៈកម្មការកិច្ចការមេធាវីវ័យក្មេង | - ប្រធានគណៈមេធាវី<br>- ក្រុមប្រឹក្សាគណៈមេធាវី | |
| ២ | | ជ្រើសរើសប្រធានលេខាធិការដ្ឋាននៃគណៈកម្មការកិច្ចការមេធាវីវ័យក្មេង | គណៈកម្មការកិច្ចការមេធាវីវ័យក្មេង | |
| ៣ | | ជ្រើសរើសធនធានមនុស្សប្រចាំការក្នុងការិយាល័យ គ.ក.ម.វ. | - ប្រធានគណៈមេធាវី<br>- គណៈកម្មការកិច្ចការមេធាវីវ័យក្មេង | |
| ៤ | **យុទ្ធសាស្ត្រទី២៖** ពង្រឹងយន្តការដែលមានស្រាប់ | ប្រជុំណែនាំដល់គ្រូកម្មសិក្សា | - គណៈកម្មការកិច្ចការមេធាវីវ័យក្មេង<br>- នាយកដ្ឋានអធិការកិច្ច<br>- នាយកដ្ឋានស្រាវជ្រាវ បោះពុម្ព និងផ្សព្វផ្សាយ | |
| ៥ | | បន្តធ្វើកម្មវិធីប្រជុំណែនាំដល់មេធាវីកំពុងធ្វើកម្មសិក្សា | - គណៈកម្មការកិច្ចការមេធាវីវ័យក្មេង<br>- នាយកដ្ឋានស្រាវជ្រាវ បោះពុម្ព និងផ្សព្វផ្សាយ | |

| | | | | |
|---|---|---|---|---|
| ៦ | | បន្តធ្វើកម្មវិធីប្រជុំណែនាំដល់មេធាវីដែលទើបចេញប្រកប វិជ្ជាជីវៈបានរយៈពេល១ឆ្នាំ | - គណៈកម្មការកិច្ចការមេធាវីវ័យក្មេង<br>- នាយកដ្ឋានស្រាវជ្រាវ បោះពុម្ព និងផ្សព្វផ្សាយ | |
| ៧ | **យុទ្ធសាស្ត្រទី៣៖**<br>បង្កើតយន្តការទ្រទ្រង់ជីវភាពមេធាវីវ័យក្មេង | ហាមឃាត់ការតម្រូវឱ្យមេធាវីកម្មសិក្សាចូលរួមវិភាគទានហិរញ្ញវត្ថុជាមួយការិយាល័យវិជ្ជាជីវៈ | - ក្រុមប្រឹក្សាគណៈមេធាវី<br>- គណៈកម្មការកិច្ចការមេធាវីវ័យក្មេង<br>- នាយកដ្ឋានអធិការកិច្ច | |
| ៨ | | បង្កើតយន្តការផ្ដល់អាទិភាពដល់មេធាវីវ័យក្មេងចំពោះសំណុំរឿងជួយជនក្រីក្រនិងស្ត្រីទូទាំងប្រទេស | - ក្រុមប្រឹក្សាគណៈមេធាវី<br>- គណៈកម្មការកិច្ចការមេធាវីវ័យក្មេង<br>- នាយកដ្ឋានការពារក្តីជូនជនក្រីក្រ | |
| **គោលដៅទី២៖ បង្កើនឱកាសការងារកាន់តែច្រើនសម្រាប់មេធាវីវ័យក្មេង** | | | | |
| ៩ | **យុទ្ធសាស្ត្រទី១៖**<br>បង្កើនការយល់ដឹងអំពីវិជ្ជាជីវៈមេធាវី | បន្តផ្សព្វផ្សាយអំពីវិជ្ជាជីវៈឱ្យបានទូលំទូលាយ | - គណៈកម្មាធិការកិច្ចមេធាវីវ័យក្មេង<br>- នាយកដ្ឋានស្រាវជ្រាវ បោះពុម្ព និងផ្សព្វផ្សាយ | |
| ១០ | | ផ្សព្វផ្សាយអំពីវិជ្ជាជីវៈមេធាវីនៅតាមសហគមន៍ទូទាំងប្រទេស៖គម្រោងមេធាវីដល់មូលដ្ឋាន | - គណៈកម្មការកិច្ចការមេធាវីវ័យក្មេង<br>- នាយកដ្ឋានស្រាវជ្រាវ បោះពុម្ព និងផ្សព្វផ្សាយ | |
| ១១ | | បង្កើតឱកាសជួបជុំរវាងមេធាវីវ័យក្មេងជាមួយពាណិជ្ជករ/អាជីវករ | គណៈកម្មការកិច្ចការមេធាវីវ័យក្មេង | |

| | | | | |
|---|---|---|---|---|
| ១២ | **យុទ្ធសាស្ត្រទី២៖**<br>បង្កើតឱកាសជួបជុំរវាងមេធាវីវ័យក្មេងនិងភាគីពាក់ព័ន្ធ | បង្កើតឱកាសជួបជុំរវាងមេធាវីវ័យក្មេងជាមួយមន្ត្រីយុត្តិធម៌ | គណៈកម្មការកិច្ចការមេធាវីវ័យក្មេង | |
| ១៣ | | បង្កើតឱកាសជួបជុំរវាងមេធាវីវ័យក្មេងជាមួយអាជ្ញាធរពាក់ព័ន្ធ | គណៈកម្មការកិច្ចការមេធាវីវ័យក្មេង | |
| ១៤ | **យុទ្ធសាស្ត្រទី៣៖**<br>កសាងភាពជាដៃគូជាមួយភាគីពាក់ព័ន្ធដើម្បីគាំទ្រមេធាវីវ័យក្មេង | បង្កើតកិច្ចសហប្រតិបត្តិការជាមួយស្ថាប័នមេធាវីបរទេសដើម្បីគាំទ្រដល់មេធាវីវ័យក្មេង | - គណៈកម្មការកិច្ចការមេធាវីវ័យក្មេង<br>- នាយកដ្ឋានទំនាក់ទំនងអន្តរជាតិ និងសាធារណៈ | |
| ១៥ | | បង្កើតកិច្ចសហប្រតិបត្តិការជាមួយក្រុមមេធាវីវ័យក្មេងបរទេស | - គណៈកម្មការកិច្ចការមេធាវីវ័យក្មេង<br>- នាយកដ្ឋានទំនាក់ទំនងអន្តរជាតិ និងសាធារណៈ | |
| **គោលដៅទី៣៖ បង្កើនជំនឿទុកចិត្តពីសង្គមលើមេធាវីវ័យក្មេង** | | | | |
| ១៦ | **យុទ្ធសាស្ត្រទី១៖**<br>បង្កើតពានរង្វាន់មេធាវីវ័យក្មេងប្រចាំឆ្នាំ | បង្កើតពានរង្វាន់លើការស្រាវជ្រាវ និងសរសេរអត្ថបទក្នុងវិស័យយុត្តិធម៌ | គណៈកម្មការកិច្ចការមេធាវីវ័យក្មេង | |
| ១៧ | | អនុវត្តការផ្តល់គ្រឿងកិត្តិយសគុណវុឌ្ឍិ និងគ្រឿងកិត្តិយសសង្គហធម៌ ចំពោះមេធាវីវ័យក្មេង | - ប្រធានគណៈមេធាវី<br>- ក្រុមប្រឹក្សាគណៈមេធាវី<br>- គណៈកម្មការកិច្ចការមេធាវីវ័យក្មេង | |
| ១៨ | **យុទ្ធសាស្ត្រទី២៖**<br>ពង្រឹងការអនុវត្តវិធានវិជ្ជាជីវៈ | ពង្រឹងការបណ្តុះបណ្តាលជាប្រចាំអំពីវិធានវិជ្ជាជីវៈដល់មេធាវីវ័យក្មេង | - មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវី<br>- គណៈកម្មការកិច្ចការមេធាវីវ័យក្មេង | |

| | | | | |
|---|---|---|---|---|
| ១៩ | និងក្រមសីលធម៌ដល់មេធាវីវ័យក្មេង | តាមដានជាប្រចាំលើការអនុវត្តវិធានវិជ្ជាជីវៈ និងក្រមសីលធម៌របស់ មេធាវីវ័យក្មេង | - គណៈកម្មការកិច្ចការមេធាវីវ័យក្មេង<br>- នាយកដ្ឋានអធិការកិច្ច | |
| ២០ | **យុទ្ធសាស្ត្រទី៣៖**<br>លើកកម្ពស់ការចូលរួមពីមេធាវីវ័យក្មេងដើម្បីផលប្រយោជន៍សាធារណៈ | បង្កើតឱកាសឱ្យមេធាវីវ័យក្មេងមានឱកាសចូលរួមក្នុងសកម្មភាពសង្គម | គណៈកម្មការកិច្ចការមេធាវីវ័យក្មេង | |
| ២១ | | បង្កើតឱកាសឱ្យមេធាវីវ័យក្មេងមានឱកាសចូលរួមសកម្មភាព ជាមួយគណៈមេធាវីនិងប្រធានគណៈមេធាវី | គណៈកម្មការកិច្ចការមេធាវីវ័យក្មេង | |
| **គោលដៅទី៤៖ បង្កើតបណ្ដុំឧបករណ៍សម្រាប់ជួយដល់ការប្រកបវិជ្ជាជីវៈរបស់មេធាវីវ័យក្មេង** | | | | |
| ២២ | **យុទ្ធសាស្ត្រទី១៖**<br>កសាងបណ្ណាល័យអេឡិចត្រូនិច | បង្កើតបណ្ណាល័យវិជ្ជាជីវៈអេឡិចត្រូនិច | - មជ្ឈមណ្ឌលបណ្ដុះបណ្ដាលវិជ្ជាជីវៈមេធាវី<br>- គណៈកម្មការកិច្ចការមេធាវីវ័យក្មេង<br>- នាយកដ្ឋានស្រាវជ្រាវ បោះពុម្ព និងផ្សព្វផ្សាយ | |
| ២៣ | | បង្កើតប្រព័ន្ធគ្រប់គ្រងនឹងផ្ដល់សេវារបស់បណ្ណាល័យអេឡិចត្រូនិច | - មជ្ឈមណ្ឌលបណ្ដុះបណ្ដាលវិជ្ជាជីវៈមេធាវី<br>- គណៈកម្មការកិច្ចការមេធាវីវ័យក្មេង<br>- នាយកដ្ឋានស្រាវជ្រាវ បោះពុម្ព និងផ្សព្វផ្សាយ | |
| ២៤ | | ចងក្រងទម្រង់ឯកសារគំរូដែលចាំបាច់ក្នុងការប្រកបវិជ្ជាជីវៈ | - គណៈកម្មការកិច្ចការមេធាវីវ័យក្មេង<br>- នាយកដ្ឋានស្រាវជ្រាវ បោះពុម្ព និងផ្សព្វផ្សាយ | |

DRAFT

| | | | | |
|---|---|---|---|---|
| ២៥ | **យុទ្ធសាស្ត្រទី២៖**<br>ចងក្រងទម្រង់ឯកសារគំរូដែលចាំបាច់ក្នុងការប្រកបវិជ្ជាជីវៈ | ចងក្រងទម្រង់ឯកសារគំរូដែលចាំបាច់ក្នុងការដំណើរការការិយាល័យមេធាវី | - គណៈកម្មការកិច្ចការមេធាវីវ័យក្មេង<br>- នាយកដ្ឋានស្រាវជ្រាវ បោះពុម្ព និងផ្សព្វផ្សាយ | |
| ២៦ | **យុទ្ធសាស្ត្រទី៣៖**<br>ចងក្រងចំណេះដឹង និងជំនាញដែលចាំបាច់ក្នុងការប្រកបវិជ្ជាជីវៈ | បង្កើតសេចក្តីណែនាំអំពីអាជីពមេធាវីសម្រាប់មេធាវីវ័យក្មេង | - គណៈកម្មការកិច្ចការមេធាវីវ័យក្មេង<br>- នាយកដ្ឋានស្រាវជ្រាវ បោះពុម្ព និងផ្សព្វផ្សាយ | |
| ២៧ | | ចងក្រងវិធីសាស្ត្រនានាអំពីការប្រកបវិជ្ជាជីវៈ | - គណៈកម្មការកិច្ចការមេធាវីវ័យក្មេង<br>- នាយកដ្ឋានស្រាវជ្រាវ បោះពុម្ព និងផ្សព្វផ្សាយ | |
| **គោលដៅទី៥៖ បង្កើតយន្តការពង្រឹងសមត្ថភាពមេធាវីវ័យក្មេង** | | | | |
| ២៨ | **យុទ្ធសាស្ត្រទី១៖**<br>ពង្រឹងគុណភាពនៃការបណ្តុះបណ្តាលផ្ទៃក្នុង | ធ្វើបច្ចុប្បន្នភាពកម្មវិធីបណ្តុះបណ្តាលផ្ទៃក្នុងឱ្យឆ្លើយតបទៅនឹងតម្រូវការរបស់មេធាវីវ័យក្មេង | មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវី | |
| ២៩ | | ធានាគុណភាពបណ្តុះបណ្តាលស្របតាមស្តង់ដារអន្តរជាតិ | មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវី | |
| ៣០ | **យុទ្ធសាស្ត្រទី២៖**<br>បណ្តុះបណ្តាលសមត្ថភាពជំនាញវិជ្ជាជីវៈមេធាវីបន្ថែម | បណ្តុះបណ្តាលសមត្ថភាពជំនាញវិជ្ជាជីវៈមេធាវីបន្ថែមរួមមាន៖<br>• ការពិគ្រោះយោបល់ជាមួយកូនក្តី<br>• ការគ្រប់គ្រងសំណុំរឿង<br>• ការគ្រប់គ្រងការិយាល័យមេធាវី<br>• ការគ្រប់គ្រងហិរញ្ញវត្ថុ | - មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវី<br>- គណៈកម្មការកិច្ចការមេធាវីវ័យក្មេង<br>- នាយកដ្ឋានស្រាវជ្រាវ បោះពុម្ព និងផ្សព្វផ្សាយ | |

| | | | | |
|---|---|---|---|---|
| | | • ការគ្រប់គ្រងស្ត្រេស<br>• ការរក្សាតុល្យភាពការងារនិងជីវិត ជាដើម។ | | |
| ៣១ | **យុទ្ធសាស្ត្រទី៣៖**<br>សហការជាមួយសាកលវិទ្យាល័យដើម្បីពង្រឹងគុណភាពមេធាវីវ័យក្មេងបន្ថែម | សហការជាមួយសាកលវិទ្យាល័យដើម្បីផ្តល់អាហារូបករណ៍ឬលក្ខខណ្ឌពិសេសដល់ការសិក្សាបន្តរបស់មេធាវីវ័យក្មេង | - គណៈកម្មការកិច្ចការមេធាវីវ័យក្មេង<br>- នាយកដ្ឋានស្រាវជ្រាវ បោះពុម្ព និងផ្សព្វផ្សាយ | |
| ៣២ | | សហការជាមួយសាកលវិទ្យាល័យដើម្បីផ្តល់ឱកាសដល់មេធាវីវ័យក្មេងចូលរួមក្នុងសកលវិទ្យាល័យ | - គណៈកម្មការកិច្ចការមេធាវីវ័យក្មេង<br>- នាយកដ្ឋានស្រាវជ្រាវ បោះពុម្ព និងផ្សព្វផ្សាយ | |

DRAFT